ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំស្តីពី ការអនុវត្តកម្មវិធីជាតិគាំពារសង្គម ដើម្បីជំរុញការចាកចេញពីភាពក្រីក្រ

# មាតិកា


**១. សារបាន** ........ 5

**២. សនិទានភាពៈ លទ្ធផល និងមេរៀនពីគម្រោងសាកល្បង** ........ 6

**៣. គោលបំណង និងគោលដៅ** ........ 8

**៤. គោលការណ៍អនុវត្តកម្មវិធី** ........ 9

**៥. យន្តការអនុវត្តកម្មវិធី** ........ 10

៥.១ ទ្រឹស្តីនៃការផ្លាស់ប្តូរ ........ 10

៥.២. ការកំណត់គ្រួសារគោលដៅ ........ 11

៥.២.១. ការជ្រើសរើសទីតាំងភូមិសាស្ត្រអាទិភាព ........ 11

៥.២.២. លក្ខខណ្ឌជ្រើសរើសគ្រួសារទទួលផល ........ 12

៥.៣. អត្ថប្រយោជន៍ និងលក្ខខណ្ឌ ........ 13

៥.៣.១. ការបណ្តុះបណ្តាល និងការបង្វឹក ........ 13

៥.៣.២. ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ចូលរួមវគ្គបណ្តុះបណ្តាល និងបង្វឹក ........ 14

៥.៣.៣. ការផ្តល់ប្រាក់ដើមទុនសម្រាប់ទិញទ្រព្យសកម្ម ........ 14

៥.៣.៤. កាចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ (Home visit and coaching) ........ 14

៥.៤. សិទ្ធិទទួលបានអត្ថប្រយោជន៍ពីកម្មវិធីគាំពារសង្គមដទៃ និងសេវាសង្គមនានា ........ 15

៥.៥. លក្ខខណ្ឌនៃការចាកចេញ ........ 16

**៦. ការឆ្លើយតបនឹងគ្រោះអាសន្ន** ........ 16

**៧. ក្របខណ្ឌអភិបាលកិច្ច** ........ 16

៧.១. ក្រុមប្រឹក្សាជាតិគាំពារសង្គម ........ 17

៧.២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ........ 18

៧.៣. ក្រសួងផែនការ ........ 18

៧.៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ........ 18

៧.៥. ក្រសួងមហាផ្ទៃ ........ 18

៧.៦. ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ........ 19
៧.៧. ក្រសួងអប់រំ យុវជន និងកីឡា ........ 19
៧.៨. ក្រសួងធម្មការ និងសាសនា ........ 19
៧.៩. ក្រសួងកិច្ចការនារី ........ 19
៧.១០. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ 20
៧.១១. មូលនិធិជាតិជំនួយសង្គមៈ ប្រតិបត្តិករបើកផ្តល់សាច់ប្រាក់ ........ 20
៧.១២. រដ្ឋបាលថ្នាក់រាជធានី-ខេត្តគោលដៅៈ ប្រតិបត្តិករដឹកនាំការអនុវត្តកម្មវិធីនៅថ្នាក់ក្រោមជាតិ ........ 20
៧.១៣. សាខាមូលនិធិជាតិជំនួយសង្គម ថ្នាក់រាជធានី-ខេត្តគោលដៅ ........ 21
៧.១៤. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ........ 21
៧.១៥. មន្ទីរផែនការ ........ 22
៧.១៦. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ 22
៧.១៧. មន្ទីរកិច្ចការនារី ........ 22
៧.១៨. រដ្ឋបាលថ្នាក់ក្រុង-ស្រុក-ខណ្ឌគោលដៅ ........ 23
៧.១៩. រដ្ឋបាលថ្នាក់ឃុំ-សង្កាត់គោលដៅ ........ 23
**៨. សកម្មភាពអន្តរកាល និងការត្រៀមខ្លួន** ........ 23
៨.១. ការរៀបចំកម្មវិធី និងក្របខណ្ឌស្ថាប័ន ........ 23
៨.២. កត្តាគាំទ្រផ្សេងទៀត ........ 24
៨.២.១.យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ........ 24
៨.២.២. ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ........ 25
៨.២.៣. ការកៀរគរធនធាន ........ 25
**៩. វដ្តប្រតិបត្តិការ និងជំហាននៃកម្មវិធី** ........ 25
៩.១. ការកំណត់ទីតាំងគោលដៅ និងការចុះឈ្មោះក្រុមគោលដៅ ........ 26
៩.២. លក្ខខណ្ឌ អនុលោមភាព និងការបើកផ្តល់សាច់ប្រាក់ ........ 27

៩.៣. ការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ ........ 28
៩.៤. ការផ្ទៀងផ្ទាត់ហិរញ្ញវត្ថុ និងការរាយការណ៍ ........ 29
៩.៥. យន្តការដោះស្រាយបណ្តឹងតវ៉ា ........ 29
៩.៥.១. បញ្ហាបច្ចេកទេសប្រចាំថ្ងៃ ........ 29
៩.៥.២. យន្តការបណ្តឹងតវ៉ា និងវិវាទ ........ 29
៩.៦. ការតាមដាន និងការវាយតម្លៃ ........ 30
៩.៦.១. ការតាមដាន ........ 30
៩.៦.២ ការវាយតម្លៃ ........ 30
**១០. ការដាក់ចេញកម្មវិធី និងផែនការពង្រីកវិសាលភាព** ........ 31
**១១. សេចក្តីសន្និដ្ឋាន** ........ 32
**ឧបសម្ព័ន្ធទី១៖ បញ្ជីទ្រព្យសកម្មសម្រាប់បង្កើតមុខរបរ** ........ 33
**ឧបសម្ព័ន្ធទី២៖ បណ្តុំសូចនាករពហុវិមាត្រ** ........ 34

## ១. សារថាន

កាលពីឆ្នាំ២០១៧ កន្លងទៅ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដើម្បីធ្វើសុខដុមនីយកម្ម ពង្រីកការគ្របដណ្តប់ និងផ្តល់អត្ថប្រយោជន៍គាំពារសង្គមជូនប្រជាពលរដ្ឋ ក្នុងគោលបំណងធានាឱ្យបាននូវសន្តិសុខប្រាក់ចំណូល, ការលើកកម្ពស់សុខុមាលភាព, ការពង្រឹងសាមគ្គីភាពសង្គម, និងការកាត់បន្ថយភាពក្រីក្រជាអតិបរមា។ ជាបន្តបន្ទាប់ គោលនយោបាយ ការកែទម្រង់ កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនានាត្រូវបានដាក់ចេញ និងអនុវត្ត ក្រោមសសរស្តម្ភទាំង ២ នៃប្រព័ន្ធគាំពារសង្គម ពោលគឺប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ជាការកត់សម្គាល់ វិសាលភាពគ្របដណ្តប់នៃប្រព័ន្ធជំនួយសង្គមត្រូវបានពង្រីកយ៉ាងឆាប់រហ័ស ពិសេសក្នុងអំឡុងការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងនោះគ្រួសារក្រីក្រចំនួនប្រមាណ ៧០០ ០០០ ត្រូវបានកំណត់អត្តសញ្ញាណ និងទទួលបានការឧបត្ថម្ភជីវភាពប្រចាំខែពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។ បន្ថែមពីនេះ នៅឆ្នាំ២០២២ រាជរដ្ឋាភិបាលបានសម្រេចកំណត់អត្តសញ្ញាណក្រុមគោលដៅជាប្រជាពលរដ្ឋរស់នៅក្បែរបន្ទាត់ភាពក្រីក្រ ដែលត្រូវបានហៅថា "**គ្រួសារងាយរងហានិភ័យ**" ហើយតាមរយៈនេះ គ្រួសារចំនួនប្រមាណ ៥០០ ០០០ បានទទួលប្រាក់ឧបត្ថម្ភពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ឆ្លើយតបនឹងគ្រោះទឹកជំនន់ធ្ងន់ធ្ងរ និងសម្ពាធអតិផរណា ដើម្បីទប់ស្កាត់កម្មវិបាកមកលើស្ថានភាពជីភាពគ្រួសារក្នុងអំឡុងវិបត្តិ។

នៅឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យអនុវត្ត "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**" ក្នុងគោលបំណងសម្រេចឱ្យបានគោលដៅអភិវឌ្ឍជាតិក្នុងការកាត់បន្ថយភាពក្រីក្រ ប្រកបដោយចីរភាព និងលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្នដើម្បីឆ្ពោះទៅសម្រេចបំណងប្រាថ្នារបស់កម្ពុជាក្លាយជាប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០។ ស្របគ្នានេះ កាលពីខែកុម្ភៈ ឆ្នាំ២០២៥ កន្លងទៅ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០២៥**" ដែលជាការធ្វើបច្ចុប្បន្នកម្ម និងជំនួសឱ្យ "**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥**" ក្នុងគោលបំណងធានានិរន្តរភាព នៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ដោយបន្តតម្រង់ទិស សម្រាប់រយៈពេល ១១ឆ្នាំ ទៅមុខ ដោយផ្តោតលើការកសាងភាពធន់ និងរក្សាភាពបត់បែនដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គ្រោះអាសន្ន និងវិបត្តិនានា ក៏ដូចជាការវិវឌ្ឍនៃកត្តាសេដ្ឋកិច្ច កត្តាសង្គម និងកត្តាប្រជាសាស្ត្រ ជាទូទៅ, សំដៅរួមចំណែកលើកកម្ពស់សុខុមាលភាពសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន។ ក្នុងន័យនេះ និងស្របតាមស្មារតី "**មិនបោះបង់ពលរដ្ឋណាម្នាក់**" ការបន្តពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង ត្រូវបានបន្តចាត់ទុកជាយុទ្ធសាស្ត្រគន្លឹះមួយ ហើយកម្មវិធីគោលនយោបាយអាទិភាពពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម ក៏ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋ ពិសេសប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ រួមមានការពង្រីកការគ្របដណ្តប់

សេវាថែទាំសុខភាពឆ្ពោះទៅការគ្របដណ្ដប់សុខភាពជាសកល, កម្មវិធីជាតិជំនួយសង្គមផ្នែកបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យចំនួនប្រមាណ ១,៥ លាននាក់, និងកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងការធ្វើស្ថាបនូន័យកម្មនៃការឆ្លើយតបនឹងគ្រោះអាសន្ន តាមរយៈប្រព័ន្ធគាំពារសង្គម។ កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវបានដាក់ឱ្យដំណើរការកាលពីខែមេសា ឆ្នាំ២០២៤ ដើម្បីបន្តផ្ដល់អត្ថប្រយោជន៍គាំពារសង្គមជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ បន្ទាប់ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានបិទបញ្ចប់។ កម្មវិធីនេះផ្ដល់ការឧបត្ថម្ភសាច់ប្រាក់គោលជូនគ្រួសារដែលមានបណ្ណសមធម៌ ព្រមទាំងសាច់ប្រាក់ឧបត្ថម្ភដែលមានលក្ខណៈសមាហរណជូនមុខសញ្ញាងាយរងគ្រោះចំនួន ៥ រួមមានស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, កុមារក្នុងវ័យសិក្សានៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា, ជនមានពិការភាព, ជនចាស់ជរា និងជនមានផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។

បន្ថែមលើវឌ្ឍនភាពថ្មីៗទាំងនេះ, តាមរយៈយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ រាជរដ្ឋាភិបាលបានកំណត់នូវកម្មវិធីគន្លឹះមួយចំនួនបន្ថែមទៀត ដើម្បីផ្ដល់ការគាំទ្របន្ថែមដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ តាមរយៈប្រព័ន្ធគាំពារសង្គម ក្នុងនោះការប្រែក្លាយគម្រោងសាកល្បងកិច្ចគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រឱ្យទៅជាកម្មវិធីជាតិ គឺជាអាទិភាពចម្បង។ ក្នុងន័យនេះ, ស្របតាមចក្ខុវិស័យដ៏ឈ្លាសវៃរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានបញ្ជាក់អំពីសារៈសំខាន់នៃ *"ការបង្រៀនពលរដ្ឋស្ទូចត្រី បន្ថែមលើការផ្ដល់ត្រីដល់ពួកគាត់"* និងផ្អែកលើលទ្ធផលវិជ្ជមាន និងបទពិសោធនៃការអនុវត្តគម្រោងសាកល្បងកិច្ចគាំពារសង្គមចាកចេញពីភាពក្រីក្រ ចាប់ពីឆ្នាំ២០២០-២០២៤, ក្រុមប្រឹក្សាជាតិគាំពារសង្គម សម្រេចរៀបចំ និងដាក់ឱ្យអនុវត្តនូវ**គោលការណ៍ណែនាំស្ដីពីការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ** ដើម្បីប្រែក្លាយគម្រោងសាកល្បងឱ្យទៅជាកម្មវិធីជាតិគាំពារសង្គមជាមួយនឹងការពង្រីកវិសាលភាពជាជំហានៗ សម្រាប់អនុវត្តរយៈពេល១០ឆ្នាំ ចាប់ពីឆ្នាំ២០២៥-២០៣៥។

## ២. សនិទានភាពៈ លទ្ធផល និងមេរៀនពីគម្រោងសាកល្បង

វិធីសាស្ត្រដើម្បីជំរុញការចាកចេញពីភាពក្រីក្រតាមរយៈប្រព័ន្ធគាំពារសង្គមនៅកម្ពុជា ត្រូវបានចាប់ផ្ដើមសិក្សាស្រាវជ្រាវលើកដំបូងក្នុងឆ្នាំ២០១៦ ក្នុងគោលបំណងលើកកម្ពស់ផលិតភាព និងភាពធន់គ្រួសារតាមរយៈការផ្ដល់សាច់ប្រាក់ឧបត្ថម្ភ រួមផ្សំនឹងការលើកកម្ពស់ជីវភាពរបស់ប្រជាជនក្រីក្រពេញវ័យនៅតាមទីជនបទ។ រាជរដ្ឋាភិបាល ដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា បានអនុវត្តគម្រោងសាកល្បងកិច្ចគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ចាប់ពីឆ្នាំ២០២០ - ២០២៤ នៅស្រុកគោលដៅ ចំនួន ២ ក្នុងខេត្តកំពង់ឆ្នាំង និងខេត្តព្រះវិហារ សំដៅលើកកម្ពស់ជីវភាព និងផ្ដល់ជូន

គ្រួសារក្រីក្រនូវគន្លងដើម្បីចាកចេញពីភាពក្រីក្រប្រកបដោយចីរភាព។ គម្រោងសាកល្បងនេះ បានកំណត់ក្រុមគោលដៅជាគ្រួសារក្រីក្រនៅតាមទីជនបទ សម្រាប់ផ្តល់ជូននូវការគាំទ្ររយៈពេល ២៤ ខែ តាមរយៈកញ្ចប់អត្ថប្រយោជន៍ រួមមានការឧបត្ថម្ភជាសាច់ប្រាក់, ទ្រព្យសកម្ម, ការបណ្តុះបណ្តាលជំនាញកសិកម្ម ជំនាញបំណិនជីវិត និងជំនាញទន់, និងការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ។ គម្រោងសាកល្បងនេះ បានបែងចែកគ្រួសារគោលដៅជា ៣ ក្រុម ដូចខាងក្រោម៖

- ក្រុមទទួលបានទ្រព្យសកម្ម (សរុបចំនួន៨០៧គ្រួសារ) ទទួលបានទ្រព្យសកម្មទៅតាមជម្រើសដែលបានផ្តល់ជូន,
- ក្រុមទទួលបានសាច់ប្រាក់ (សរុបចំនួន ៧៧៣គ្រួសារ) ទទួលសាច់ប្រាក់ជាដើមទុន សម្រាប់ទិញទ្រព្យសកម្មដោយខ្លួនឯង និង
- ក្រុមមិនទទួលបានអន្តរាគមន៍ (Control group) ចំនួន៨០៤គ្រួសារ។

ចំពោះដំណើរការនៃគម្រោងសាកល្បងនេះ, មូលនិធិជាតិជំនួយសង្គម ទទួលបន្ទុកបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភប្រចាំខែ ព្រមទាំងប្រាក់ដើមទុន។ រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការគាំទ្រ និងសហការពីអង្គការទស្សនៈពិភពលោកអន្តរជាតិ ទទួលបន្ទុកផ្តល់ទ្រព្យសកម្ម និងផ្តល់ការបណ្តុះបណ្តាល ហើយក្រោមការគ្រប់គ្រង និងចាត់ចែងពីអាជ្ញាធរមូលដ្ឋាន, យុវជនស្ម័គ្រចិត្តតាមសហគមន៍ ទទួលបន្ទុកចុះសួរសុខទុក្ខ និងបង្វឹកគ្រួសារតាមខ្នងផ្ទះជាប្រចាំ។

**រូបភាពទី១៖** លទ្ធផលវិជ្ជមានរបស់ក្រុមទទួលបានអន្តរាគមន៍ ធៀបនឹងក្រុមមិនទទួលបានអន្តរាគមន៍ តាមរយៈការវាយតម្លៃកម្មវិបាកចុងក្រោយនៃគម្រោងសាកល្បងកិច្ចគាំពារសង្គមដើម្បីចាកចេញពីភាពក្រីក្រ




ដើម្បីពិនិត្យវឌ្ឍនភាព និងលទ្ធផលពីការអនុវត្តគម្រោងសាកល្បង, ការវាយតម្លៃកម្មវិបាកត្រូវបានរៀបចំឡើង ដោយប្រៀបធៀបលទ្ធផលរវាងក្រុមទទួលបានអន្តរាគមន៍ទាំង២ និងក្រុមដែលមិនទទួលបានអន្តរាគមន៍ (Control group)។ លទ្ធផលនៃការវាយតម្លៃកម្មវិបាកបានបង្ហាញថា វិធីសាស្ត្រដើម្បី

ការជំរុញការចាកចេញពីភាពក្រីក្រនេះ ជាម៉ូដែលដែលមានប្រសិទ្ធភាពសម្រាប់ការកសាង និងបង្កើនទ្រព្យសកម្ម និងហិរញ្ញវត្ថុ និងមូលធនសង្គមរបស់គ្រួសារក្រីក្រ ព្រមទាំងបង្កើតគន្លងដើម្បីជំរុញគ្រួសារក្នុងការលើកកម្ពស់ជីវភាព និងចាកចេញពីភាពក្រីក្រ។ ទិន្នន័យបានបង្ហាញថា អត្រាភាពក្រីក្ររបស់គ្រួសារមានបណ្ណសមធម៌ដែលទទួលបានអន្តរាគមន៍ បានធ្លាក់ចុះចំនួន ១៨.៨% ខណៈដែលប្រាក់ចំណូលមានការកើនឡើងចំនួន ៣៨.៦% និងចំណាយសមាជិកម្នាក់ប្រចាំថ្ងៃមានការកើនឡើងចំនួន ១៣% ធៀបនឹងគ្រួសារមិនទទួលបានអន្តរាគមន៍។ ទន្ទឹមនេះ គ្រួសារមួយចំនួនក៏សម្រេចបាននូវការចាកចេញពីភាពក្រីក្រលក្ខណៈពហុលក្ខខណ្ឌ (Multiple poverty graduation criteria) ដែលនេះបង្ហាញពីស្ថិរភាពសេដ្ឋកិច្ចរយៈពេលវែងប្រកបដោយភាពធន់នៃគ្រួសារទាំងនេះ។ គ្រួសារទទួលបានអន្តរាគមន៍ក៏ត្រូវបានពិនិត្យឃើញថាមានភាពប្រសើរឡើងពាក់ព័ន្ធនឹងឥរិយាបទសន្សំថវិកា, អក្ខរកម្មហិរញ្ញវត្ថុ, និងការប្រើប្រាស់សេវាកម្មធនាគារ ផងដែរ។

ផ្អែកលើបទពិសោធ និងលទ្ធផលនៃការវាយតម្លៃការអនុវត្តគម្រោងសាកល្បងកិច្ចគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ, កត្តាចំនួន ៤ ត្រូវបានពិនិត្យឃើញថាបានជះឥទ្ធិពលលើលទ្ធផលនៃគម្រោងសាកល្បង រួមមាន៖ ១) វ័យរបស់មេគ្រួសារ, ២) មេគ្រួសារជាបុរស ឬស្ត្រី, ៣) ផ្នត់គំនិតរបស់អ្នកចូលរួម និងសមត្ថភាពបុគ្គល, និង ៤) ការទទួលបានសេវាបច្ចេកទេសកសិកម្ម។ ក្នុងន័យនេះ លទ្ធផលនៃការវាយតម្លៃ បានបង្ហាញថា គ្រួសារដែលមិនមានដីធ្លី ឬមានសមាជិកជាអនក្ខរជន ក៏ដូចជាគ្រួសារមានមេគ្រួសារអាយុច្រើនជាង៦០ឆ្នាំ ឬមានភាពងាយរងហានិភ័យធ្ងន់ធ្ងរ (មានជំងឺរ៉ាំរ៉ៃ) មានការប្រឈមក្នុងការបង្កើនផលិតភាព និងប្រាក់ចំណូល។ គ្រួសារមានចាស់ជរាជាមេគ្រួសារទទួលបានប្រាក់ចំណូល ៣៦% តិចជាងគ្រួសារមានមេគ្រួសារមានអាយុតិចជាង៦០ឆ្នាំ ជាមធ្យម។ គ្រួសារមានមេគ្រួសារជាអក្ខរជនទទួលបានប្រាក់ចំណូល ៤០% ច្រើនជាគ្រួសារមានមេគ្រួសារជាអនក្ខរជន ជាមធ្យម។ គ្រួសារមានមេគ្រួសារជាបុរស មានសមត្ថភាពរកប្រាក់ចំណូល និងលទ្ធភាពចាកចេញពីភាពក្រីក្រ ខ្ពស់ជាងគ្រួសារមានមេគ្រួសារជាស្ត្រី។ ប៉ុន្តែជាទូទៅ ស្ត្រីបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមក្នុងកម្មវិធី ការរៀបចំផែនការអាជីវកម្ម និងគោរពលក្ខខណ្ឌនៃកម្មវិធី និងការណែនាំសម្រាប់អាជីវកម្ម។ កត្តាដូចបានរៀបរាប់ខាងលើទាំងនេះត្រូវបានគិតគូរសម្រាប់ការរៀបចំកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ។

## ៣. គោលបំណង និងគោលដៅ

គោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ត្រូវបានរៀបចំឡើង ដើម្បីរៀបចំ និងដាក់ឱ្យដំណើរការកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ប្រកបដោយប្រសិទ្ធភាព សម្រាប់រយៈពេល ១០ឆ្នាំ ចាប់ពីឆ្នាំ២០២៥-២០៣៥ ដោយធ្វើការកំណត់នូវសមាសធាតុ និងនីតិវិធីសំខាន់ៗ រួមមានគោលការណ៍អនុវត្ត ក្រុមគោលដៅ និងលក្ខខណ្ឌ

ទទួលផល កញ្ចប់អត្ថប្រយោជន៍ យន្តការស្ថាប័ន សកម្មភាពអន្តរកាល និងការត្រៀមខ្លួន និងវដ្តនៃការគ្រប់គ្រងកម្មវិធី ព្រមទាំងផែនការអនុវត្ត និងពង្រីកវិសាលភាពកម្មវិធី។

តាមរយៈការដាក់ចេញនូវ **កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ**, រាជរដ្ឋាភិបាលមានគោលបំណងកសាងសមត្ថភាព ភាពធន់ ព្រមទាំងលើកកម្ពស់ជីវភាពរបស់គ្រួសារក្រីក្រ ដើម្បីឱ្យគ្រួសារគោលដៅមានសមត្ថភាពចាកចេញពីភាពក្រីក្រជាជំហានៗ និងប្រកបដោយចីរភាព ព្រមទាំងចូលរួមចំណែកក្នុងការលើកកម្ពស់ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ស្របតាមចក្ខុវិស័យ *"បង្រៀនពលរដ្ឋស្ទូចត្រី បន្ថែមលើការផ្តល់ត្រីដល់ពួកគាត់"*។ កម្មវិធីនេះមានគោលដៅជាក់លាក់ដូចខាងក្រោម៖

- ផ្តល់ការគាំទ្រផ្នែកជំនួយសង្គមប្រកបដោយប្រសិទ្ធភាព ដោយបញ្ចូលការបណ្តុះបណ្តាល និងការបង្វឹកជំនាញ និងបំណិនជីវិត សហគ្រិនភាព ការផ្លាស់ប្តូរឥរិយាបថ និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់គ្រួសារក្រីក្រប្រកបដោយចីរភាព រួមទាំងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ
- បង្កើនសមត្ថភាព និងភាពធន់របស់គ្រួសារក្រីក្រក្នុងការគ្រប់គ្រងហានិភ័យផ្សេងៗ រួមទាំងហានិភ័យពីការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើនទ្រព្យសម្បត្តិ និងប្រាក់សន្សំ និងការធ្វើពិពិធកម្មប្រាក់ចំណូល ព្រមទាំងជួយលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន
- ជំរុញការទទួលឱកាសទីផ្សារសម្រាប់គ្រួសារក្រីក្រ រួមទាំងការតភ្ជាប់កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ជាមួយកម្មវិធីគាំពារសង្គមដែលមានស្រាប់នានា និងអនុវត្តការបញ្ជូនបន្តទៅសេវាបំពេញបន្ថែមផ្សេងៗទៀត និង
- ពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីនានា ក្នុងប្រព័ន្ធគាំពារសង្គម។

## ៤. គោលការណ៍អនុវត្តកម្មវិធី

គោលការណ៍អនុវត្ត **កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ** សំខាន់ៗ មានចំនួន ៥ ដូចតទៅ៖

- **ការអនុវត្តជាជំហាន៖** ដាក់អនុវត្តកម្មវិធីជាជំហានៗ ដើម្បីធានាបាននូវអន្តរកាលពីគម្រោងសាកល្បងទៅជាកម្មវិធីជាតិដោយរលូន ជាពិសេសការពង្រីកវិសាលភាពនៅតំបន់គោលដៅនៃគម្រោងសាកល្បងសម្រាប់ជំហានដំបូង ព្រមទាំងបន្តដកស្រង់បទពិសោធពីការអនុវត្តកម្មវិធីជាបន្តបន្ទាប់
- **ចីរភាពហិរញ្ញវត្ថុ៖** គិតគូរពីទំហំសារពើពន្ធដែលមានក្នុងស្រុក និងធានាចីរភាពការអនុវត្តកម្មវិធី និងការផ្តល់ហិរញ្ញប្បទាន

- ប្រសិទ្ធភាព និងការបំពេញបន្ថែម៖ ធ្វើឱ្យប្រសើរឡើងនូវផលិតភាពរបស់គ្រួសារក្រីក្រ ដើម្បីជួយលើកស្ទួយដល់ជីវភាពរស់នៅ និងសុខុមាលភាព តាមរយៈការផ្សារភ្ជាប់ជាមួយកម្មវិធីគាំពារសង្គម និងសេវានានាដែលមានស្រាប់
- ការឆ្លើយតបនឹងយេនឌ័រ៖ គិតគូរឆ្លើយតបតាមតម្រូវការជាក់លាក់របស់ស្ត្រី សម្រាប់ការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាលើកទឹកចិត្តឱ្យមានការចូលរួមរបស់ស្ត្រីជាមេគ្រួសារ និងដាក់បញ្ចូលទិដ្ឋភាពយេនឌ័រក្នុងកម្មវិធីបណ្តុះបណ្តាល និងការតាមដាន និងវាយតម្លៃ និង
- ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖ គិតគូរពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងគ្រោះអាសន្នផ្សេងៗ ដោយអភិវឌ្ឍជីវភាពរស់នៅ និងប្រភពចំណូលរបស់គ្រួសារប្រកបដោយចីរភាព និងមានភាពធន់។

## ៥. យន្តការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ

### ៥.១ ទ្រឹស្តីនៃការផ្លាស់ប្តូរ

រូបភាពទី២៖ ក្របខណ្ឌតក្កភាពនៃការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ



ក្របខណ្ឌតក្កភាពដូចមានក្នុងរូបភាពទី២ បង្ហាញអំពីលទ្ធផលនៅគ្រប់កម្រិតនៃការអនុវត្តកម្មវិធីនេះសម្រាប់រយៈពេលខ្លី, មធ្យម, និងវែង នៅកម្រិតបុគ្គល និងគ្រួសារ ទាំងដោយផ្ទាល់ និងប្រយោលដូចខាងក្រោម៖

- រយៈពេលខ្លី (ជាតុចេញ)៖ ភាពប្រសើរឡើងនៃស្ថានភាពសេដ្ឋកិច្ច និងសន្តិសុខស្បៀង បន្ទាប់ពីការកើនឡើងនៃសាច់ប្រាក់សម្រាប់ចំណាយលើតម្រូវការមូលដ្ឋាន តាមរយៈការទទួលបានពីកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសាររួមទាំងសាច់ប្រាក់ឧបត្ថម្ភបន្ថែមពីការចូលរួមវគ្គបណ្តុះបណ្តាល។ ការផ្លាស់ប្តូរសកម្មភាពប្រើប្រាស់ពេលរបស់សមាជិកគ្រួសារគោលដៅ ដូចជាកំណើននៃការចូលរួមក្នុងសកម្មភាពផលិតកម្ម និងការកើនឡើងនៃចំណេះដឹងផ្នែកកសិកម្ម ភាពចម្រុះនៃរបបអាហារ និងអក្ខរកម្មហិរញ្ញវត្ថុ។
- រយៈពេលមធ្យម (លទ្ធផល)៖ ភាពប្រសើរឡើងនៃផលិតភាពកសិកម្ម ពិពិធកម្មដំណាំ និង/ឬសត្វចិញ្ចឹម និងទ្រព្យសកម្មផ្សេងៗ, ការកើនឡើងនៃប្រាក់ចំណូល និងប្រាក់សន្សំ ព្រមទាំងលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ, និងការកើនឡើងនៃភាពអង់អាចរបស់អ្នកទទួលផល ពិសេសស្ត្រី និងការកើនឡើងនៃសមត្ថភាពរបស់អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តការងារ។
- រយៈពេលវែង (កម្មវិបាក)៖ កាត់បន្ថយភាពក្រីក្រផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ, ការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន, ការបង្កើនសមាហរណកម្មសម្រាប់ទទួលបានឱកាសទីផ្សារ, ការបង្កើនចំណងសង្គម (Social tie) កាន់តែរឹងមាំ, ការទទួលបានសេវានានាកាន់តែ ប្រសើរឡើង និងការពង្រឹងភាពធន់ទៅនឹងគ្រោះអាសន្នផ្សេងៗ។

## ៥.២. ការកំណត់គ្រួសារគោលដៅ

កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ត្រូវពង្រីកវិសាលភាពជាបន្តបន្ទាប់ទៅកាន់ទីតាំងភូមិសាស្ត្រអាទិភាពនានានៅទូទាំងប្រទេស។ ក្នុងន័យនេះ ដំណើរការជ្រើសរើសគ្រួសារគោលដៅឱ្យចូលរួមកម្មវិធី ត្រូវអនុវត្តជា ២ ជំហានសំខាន់ៗ ដូចជា៖ ១) ការជ្រើសរើសទីតាំងភូមិសាស្ត្រអាទិភាព និង ២)ការជ្រើសរើសគ្រួសារគោលដៅ។

### ៥.២.១. ការជ្រើសរើសទីតាំងភូមិសាស្ត្រអាទិភាព

លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ទីតាំងភូមិសាស្ត្រអាទិភាព មានដូចខាងក្រោម៖

- អត្រាភាពក្រីក្រខ្ពស់,
- ហានិភ័យខ្ពស់ពីការប្រែប្រួលអាកាសធាតុ, និង
- អត្រាសន្តិសុខស្បៀងទាប។

ជាការគិតគូរដំបូង ការអនុវត្តកម្មវិធីនឹងផ្តល់អាទិភាពសម្រាប់ទីតាំងភូមិសាស្ត្រដែលបានអនុវត្តគម្រោងសាកល្បង ដែលសមត្ថភាពស្ថាប័នត្រូវបានពង្រឹង នាពេលកន្លងមក។ បន្ថែមលើនេះ ការអនុវត្តកម្មវិធីនឹងគិតគូរផ្តល់អាទិភាពសម្រាប់ទីតាំងភូមិសាស្ត្រមានដំណើរការកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ដែលនៅមានបញ្ហាផ្គត់ផ្គង់អាហារនៅឡើយ។ ការណ៍នេះនឹងចូលរួមចំណែកដោះស្រាយបញ្ហាផ្គត់ផ្គង់ និងពង្រឹងច្រវ៉ាក់ផ្គត់ផ្គង់សម្រាប់កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ព្រមទាំងជានាបានឱកាសទីផ្សារសម្រាប់គ្រួសារទទួលផល។

ផ្អែកតាមលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ទីតាំងភូមិសាស្ត្រ, បញ្ជីពង្រីកវិសាលភាពរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ គោលដៅនឹងត្រូវរៀបចំ និងកំណត់ជារៀងរាល់ឆ្នាំ។

### ៥.២.២. លក្ខខណ្ឌជ្រើសរើសគ្រួសារទទួលផល

បន្ទាប់ពីបានជ្រើសរើសស្រុក-ឃុំគោលដៅសម្រាប់អនុវត្ត, លក្ខខណ្ឌជ្រើសរើសគ្រួសារ មានចំនួន ២ សំខាន់ៗ ដើម្បីចូលរួមក្នុងកម្មវិធី ដូចខាងក្រោមៈ

- ត្រូវមានបណ្ណសមធម៌ ក្រ១ ឬក្រ២ ដែលកំពុងរស់នៅក្នុងឃុំ និងស្រុកដែលបានជ្រើសរើស, និង
- ត្រូវមានសមាជិកគ្រួសារយ៉ាងតិចមួយរូបដែលមានអាយុចាប់ពី១៥ឆ្នាំ ដល់៦៥ឆ្នាំ ដែលអាចមានលទ្ធភាពពលកម្មដើម្បីចូលរួមពេញលេញនៅក្នុងកម្មវិធី។

## ៥.៣. អត្ថប្រយោជន៍ និងលក្ខខណ្ឌ

កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ មានកាលកំណត់សម្រាប់អនុវត្តជាក់លាក់ ដែលតម្រូវឱ្យគ្រួសារគោលដៅចូលរួមក្នុងកម្មវិធីសម្រាប់រយៈពេល ២៤ ខែ។ ក្នុងអំឡុងនៃកម្មវិធី, គ្រួសារគោលដៅត្រូវទទួលបានកញ្ចប់អត្ថប្រយោជន៍ ដូចខាងក្រោម៖




រូបភាពទី៣៖ កញ្ចប់អត្ថប្រយោជន៍ នៃកម្មវិធី

### ៥.៣.១. ការបណ្តុះបណ្តាល និងការបង្វឹក

ការបណ្តុះបណ្តាល និងការបង្វឹកត្រូវផ្តោតលើការបង្កើតមុខរបរបំណិនជីវិត,បរិយាបន្នហិរញ្ញវត្ថុ,ការផ្លាស់ប្តូរឥរិយាបថរស់នៅ ក៏ដូចជាផ្នែកដទៃទៀត ហើយត្រូវអនុវត្តជារៀងរាល់សប្តាហ៍ សម្រាប់រយៈពេល ៣ខែ ចាប់ពីខែទី១-៣ នៃវដ្តកម្មវិធី ដោយផ្តោតសំខាន់លើ៖

- **ការបង្កើតមុខរបរ និងបំណិនជីវិត៖** ផ្តោតលើការគ្រប់គ្រងទ្រព្យសកម្ម និងដំណើរការអាជីវកម្មពាក់ព័ន្ធ
- **បរិយាបន្នហិរញ្ញវត្ថុ៖** គាំទ្រ និងបង្កើនសមត្ថភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ ការវិនិយោគប្រកបដោយភាពឈ្លាសវៃ ព្រមទាំងការគ្រប់គ្រងហានិភ័យ និងគ្រប់គ្រងអាជីវកម្ម តាមរយៈការបណ្តុះបណ្តាលបរិយាបន្នហិរញ្ញវត្ថុ និងលើកកម្ពស់វប្បធម៌សន្សំប្រាក់ និង

- **ការផ្លាស់ប្តូរឥរិយាបថរស់នៅ៖** ដោះស្រាយបញ្ហាផ្នត់គំនិតគ្រួសារដែលនាំឱ្យមានភាពក្រីក្រ និងជំរុញការអភិវឌ្ឍមូលធនមនុស្ស, ការគិតវិជ្ជមានអំពីគ្រួសារ, និងទម្លាប់វិនិយោគ តាមរយៈវគ្គបណ្តុះបណ្តាលស្តីពីការផ្លាស់ប្តូរឥរិយាបថរស់នៅ។ វគ្គបណ្តុះបណ្តាលនេះនឹងផ្តោតសំខាន់លើប្រធានបទចម្បងៗ ដូចជាអាហារូបត្ថម្ភ និងភាពចម្រុះនៃរបបអាហារ, ការបង្ការ និងថែទាំសុខភាព, អនាម័យ និងទឹកស្អាត, ការសិក្សារបស់កុមារ, ការគ្រប់គ្រងគ្រោះមហន្តរាយ និងបន្សុំនឹងការប្រែប្រួលអាកាសធាតុ, និងយេនឌ័រ។

បន្ថែមលើនេះ កម្មវិធីនឹងរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំង និងវគ្គបណ្តុះបណ្តាល និងបង្វឹកដើម្បីរំលឹកមេរៀនឡើងវិញ សំដៅធានាថាគ្រួសារគោលដៅអាចទទួល និងប្រើប្រាស់ចំណេះដឹងបានពេញលេញ ដែលនេះនាំឱ្យសមត្ថភាពគ្រួសារមានភាពប្រសើរឡើង។ ព័ត៌មានលម្អិតអំពីវគ្គបណ្តុះបណ្តាលមានក្នុងតារាងទី១។

### ៥.៣.២. ការឧបត្ថម្ភសាច់ប្រាក់សម្រាប់ចូលរួមវគ្គបណ្តុះបណ្តាល និងបង្វឹក

ខណៈដែលសាច់ប្រាក់ឧបត្ថម្ភរបស់កម្មវិធីជាតិជំនួយសង្គមជួយសម្រួលដល់ចំណាយជាមូលដ្ឋានរបស់គ្រួសារក្រីក្រ, កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រផ្តល់សាច់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់លើកទឹកចិត្តគ្រួសារ និងរ៉ាប់រងលើចំណាយចូលរួមវគ្គបណ្តុះបណ្តាល និងបង្វឹក និងកិច្ចប្រជុំនានាឱ្យបានពេញលេញតាមការកំណត់នៃកម្មវិធី។ ព័ត៌មានលម្អិតអំពីការឧបត្ថម្ភសាច់ប្រាក់ និងលក្ខខណ្ឌទទួលបានអត្ថប្រយោជន៍មានក្នុងតារាងទី១។

### ៥.៣.៣. ការផ្តល់ប្រាក់ដើមទុនសម្រាប់ទិញទ្រព្យសកម្ម

បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល និងការបង្វឹកតាមការកំណត់, កម្មវិធីនេះផ្តល់ប្រាក់ដើមទុនមួយលើកសម្រាប់ចំណាយលើការទិញទ្រព្យសកម្ម (ដូចក្នុងបញ្ជីទ្រព្យសកម្មក្នុងឧបសម្ព័ន្ធទី១) ដើម្បីបង្កើត និងប្រកបមុខរបរ។ ការទិញទ្រព្យសកម្ម ត្រូវផ្តល់អាទិភាពសម្រាប់មូលដ្ឋានដែលគ្រួសារទទួលផលបាន និងកំពុងរស់នៅដោយផ្ទាល់ ដោយមានការគាំទ្រ និងសម្របសម្រួលពីរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្តល់ប្រាក់ដើមទុនសម្រាប់ទិញទ្រព្យសកម្មអនុញ្ញាតឱ្យគ្រួសារមានលទ្ធភាពបង្កើនសមត្ថភាពផលិត និងរកប្រាក់ចំណូលនៅមូលដ្ឋានផ្ទាល់ ដោយប្រើប្រាស់ចំណេះដឹង និងជំនាញទទួលបានពីវគ្គបណ្តុះបណ្តាល និងបង្វឹក។

### ៥.៣.៤. ការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ (Home visit and coaching)

ការចុះសួរសុខទុក្ខ និងបង្វឹកតាមផ្ទះ ត្រូវអនុវត្តជាប្រចាំក្នុងវដ្តនៃកម្មវិធី រួមទាំងការពិភាក្សាជាមួយគ្រួសារទទួលផលតាមទូរសព្ទផងដែរ ហើយអាស្រ័យលើវឌ្ឍភាពរបស់គ្រួសារ ការគាំទ្របន្ថែម និងការចុះសួរសុខទុក្ខអាចអនុវត្តជាញឹកញាប់ ពិសេសក្នុងដំណាក់កាលសំខាន់ៗនៃកម្មវិធី ដូចជាបន្ទាប់ពីគ្រួសារទទួលបានប្រាក់ដើមទុនសម្រាប់ទិញទ្រព្យសកម្ម។ ការអនុវត្តចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះនេះក៏ជាការតាមដានវឌ្ឍនភាពរបស់គ្រួសារជាប្រចាំ ដើម្បីប្រៀបធៀបលទ្ធផលនឹងផែនការអាជីវកម្ម ដោះស្រាយ

បញ្ហាប្រឈមនានា និងផ្តល់ការតម្រង់ទិស គាំទ្រ និងលើកទឹកចិត្តបន្ថែមដល់គ្រួសារក្នុងការកសាងជំនាញទន់ ការផ្លាស់ប្តូរឥរិយាបថ និងការធ្វើវិនិយោគរបស់គ្រួសារ។

តារាងទី១៖ កញ្ចប់អត្ថប្រយោជន៍ កាលវិភាគ និងលក្ខខណ្ឌ នៃកម្មវិធី

| ល.រ | កញ្ចប់អត្ថប្រយោជន៍ | កាលវិភាគ | លក្ខខណ្ឌទទួលផល | ចំនួនប្រាក់ឧបត្ថម្ភ |
|---|---|---|---|---|
| ការផ្តល់ទ្រព្យសកម្ម | | | | |
| ១ | កញ្ចប់ប្រាក់ដើមទុនសម្រាប់ទិញទ្រព្យសកម្ម | ខែទី៤ | ចូលរួមវគ្គបណ្តុះបណ្តាលចំនួន៨ក្នុងចំណោម១១ ដូចបានកំណត់ក្នុងខែទី១-៣ | ៩៦០ ០០០រៀល |
| សាច់ប្រាក់ឧបត្ថម្ភ និងវគ្គបណ្តុះបណ្តាល និងបង្វឹកអំពីមុខរបរ និងបំណិនជីវិត | | | | |
| ១ | ការណែនាំអំពីកម្មវិធី | ខែទី១ (សប្តាហ៍ទី១) | ចូលរួមវគ្គបណ្តុះបណ្តាល ៣ក្នុងចំណោម៤ | ៤០ ០០០រៀល |
| ២ | ផែនការគ្រួសារ | ខែទី១ (សប្តាហ៍ទី២-៣) | | |
| ៣ | ចំណេះដឹងហិរញ្ញវត្ថុ | ខែទី១ (សប្តាហ៍ទី៣-៤) | | |
| ៤ | សហគ្រិនភាព និងផែនការអាជីវកម្មខ្នាតតូច | ខែទី១ (សប្តាហ៍ទី៣-៤) | | |
| ៥ | ការលើកកម្ពស់សុខភាពអនាម័យ | ខែទី២ (សប្តាហ៍ទី១-២) | ចូលរួមវគ្គបណ្តុះបណ្តាល ២ក្នុងចំណោម៣ | ៤០ ០០០រៀល |
| ៦ | អាហារូបត្ថម្ភ និងសុខភាព | ខែទី២ (សប្តាហ៍ទី១-២) | | |
| ៧ | គ្រួសារ និងយេនឌ័រ | ខែទី២ (សប្តាហ៍ទី៣-៤) | | |
| ៨ | គុណតម្លៃនៃការអប់រំ | ខែទី២ (សប្តាហ៍ទី៣-៤) | ចូលរួមវគ្គបណ្តុះបណ្តាល ២ក្នុងចំណោម៣ | ៤០ ០០០រៀល |
| ៩ | កិច្ចគាំពារកុមារ | ខែទី៣ (សប្តាហ៍ទី១-២) | | |
| ១០ | ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ខែទី៣ (សប្តាហ៍ទី១-២) | | |
| ១១ | វគ្គបណ្តុះបណ្តាល និងបង្វឹកជំនាញ | ខែទី៣ (សប្តាហ៍ទី៣-៤) | ចូលរួមវគ្គបណ្តុះបណ្តាល | ៤០ ០០០រៀល |
| ១២ | កិច្ចប្រជុំឆ្លុះបញ្ចាំង | ខែទី៦-១២ | ចូលរួមវគ្គបណ្តុះបណ្តាល | ៤០ ០០០រៀល |
| ១៣ | វគ្គបំប៉នៈជំនាញបំណិនជីវិតនិងការផ្លាស់ប្តូរឥរិយាបថ (គ្រប់មេរៀន) | ខែទី១២-១៥ | ចូលរួមវគ្គបណ្តុះបណ្តាល | ៤០ ០០០រៀល |
| ១៤ | វគ្គបំប៉នៈបង្វឹកជំនាញ | ខែទី១២-១៥ | ចូលរួមវគ្គបណ្តុះបណ្តាល | ៤០ ០០០រៀល |
| ការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ | | | | |
| ១ | ការបង្វឹកនិងការផ្តល់ប្រឹក្សាយោបល់ដល់គ្រួសារ | រៀងរាល់ខែ ចាប់ពីខែទី១ ដល់ខែទី២៤ | - | - |
| សរុប | | ១ ២៤០ ០០០ រៀល | | |

## ៥.៤. សិទ្ធិទទួលបានអត្ថប្រយោជន៍ពីកម្មវិធីគាំពារសង្គមដទៃ និងសេវាសង្គមនានា

គ្រួសារដែលចូលរួមក្នុងកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ អាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធី ដូចបានកំណត់ខាងលើ។ បន្ថែមលើនេះ គ្រួសារទាំងនេះអាចបន្តទទួលបានអត្ថប្រយោជន៍នានាពីកម្មវិធីគាំពារសង្គម ព្រមទាំងសេវាសង្គម ទៅតាមសិទ្ធិ និងលក្ខខណ្ឌនៃកម្មវិធី និងសេវា។

គ្រួសារទទួលផលដែលបានចុះឈ្មោះចូលរួមក្នុងកម្មវិធីត្រូវជានាឱ្យបានការចូលរួមឱ្យបានសកម្ម និងពេញលេញ។ គ្រួសារទទួលផលមានសមាជិកមានលទ្ធភាពពលកម្មតែមួយរូប មិនអាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យក្នុងពេលដំណាលគ្នានោះទេ។

### ៥.៥. លក្ខខណ្ឌនៃការចាកចេញ

លក្ខខណ្ឌនៃការចាកចេញទូទៅសម្រាប់គ្រួសារទទួលផលនៃកម្មវិធី មានដូចខាងក្រោម៖

- **ការល្មើសកិច្ចព្រមព្រៀង៖** លក្ខខណ្ឌអនុវត្តត្រូវបានកំណត់សម្រាប់គ្រួសារទទួលផល ហើយក្នុងករណីគ្រួសារណាត្រូវបានរកឃើញថាល្មើសកិច្ចព្រមព្រៀងធ្ងន់ធ្ងរ (និងមានភស្តុតាង) រួមទាំងការប្រើប្រាស់ប្រាក់ឧបត្ថម្ភខុសគោលដៅ អាចត្រូវបានដកចេញពីកម្មវិធី
- **ការក្លែងបន្លំ/ប្រតិដ្ឋព័ត៌មានមិនពិត៖** គ្រួសារណាដែលផ្តល់ព័ត៌មានក្លែងបន្លំ (ករណីមានភស្តុតាង) អាចត្រូវបានដកចេញពីកម្មវិធី និង
- **ការបាត់បង់សមត្ថភាពចូលរួមកម្មវិធី៖** គ្រួសារណាដែលបានបាត់សមត្ថភាពចូលរួមក្នុងកម្មវិធីដោយសារសមាជិកតែមួយរូបដែលមានលទ្ធភាពពលកម្មធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ឬទទួលមរណភាព អាចត្រូវបានដកចេញពីកម្មវិធី។

## ៦. ការឆ្លើយតបនឹងគ្រោះអាសន្ន

គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល កាលពីឆ្នាំ២០២៣ កន្លងទៅ ក្នុងគោលបំណងគាំទ្រការប្រើប្រាស់ប្រព័ន្ធគាំពារសង្គមដែលអាចព្យាករបាន ទាន់ពេល និងប្រកបដោយប្រសិទ្ធិភាព សម្រាប់ផ្តល់ការគាំពារដល់ប្រជាពលរដ្ឋពិសេសប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ពីគ្រោះអាសន្ននានារួមទាំងគ្រោះមហន្តរាយធម្មជាតិ វិបត្តិម៉ាក្រូសេដ្ឋកិច្ច និងគ្រោះអាសន្នពីវិបត្តិសុខភាពសាធារណៈ។ ស្របតាមគោលការណ៍ណែនាំនេះ កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ត្រូវពិនិត្យលទ្ធភាពកែសម្រួលយន្តការ និងដំណើរការនៃកម្មវិធី ក្នុងករណីមានគ្រោះអាសន្នកើតឡើង សំដៅកាត់បន្ថយកម្មវិបាកដល់ដំណើរការ និងធានាឱ្យបានប្រសិទ្ធភាពនៃកម្មវិធី។

អាស្រ័យលើប្រភេទ និងកម្រិតធ្ងន់ធ្ងរនៃគ្រោះអាសន្ននានា,វិធីសាស្ត្រ ដូចខាងក្រោម ត្រូវបានប្រើប្រាស់ក្នុងចំណោមវិធីសាស្ត្រផ្សេងទៀត៖

- **ការកែសម្រួលយន្តការ៖** ការកែសម្រួលយន្តការផ្តល់វគ្គបណ្តុះបណ្តាល និងការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ ឬព្យួរការផ្តល់វគ្គបណ្តុះបណ្តាល ដោយនៅតែបន្តការផ្តល់ប្រាក់ឧបត្ថម្ភ និង
- **ការពង្រីកវិសាលភាពតាមខ្សែបញ្ឈរ៖** បន្ថែមទំហំប្រាក់ឧបត្ថម្ភសម្រាប់ការចូលរួមវគ្គបណ្តុះ-បណ្តាល និង/បន្ថែមទំហំប្រាក់ឧបត្ថម្ភសម្រាប់ទិញទ្រព្យសកម្ម។

## ៧. ក្របខណ្ឌអភិបាលកិច្ច

កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ស្ថិតនៅក្រោមការតម្រង់ទិសជារួមរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាសេនាធិការ

និងជាភ្នាក់ងារប្រតិបត្តិ (Executive agency) និងមានភ្នាក់ងារអនុវត្ត(Implementing agency) គោលចំនួន ២ រួមមាន មូលនិធិជាតិជំនួយសង្គម និងរដ្ឋបាលរាជធានី ខេត្ត។ ជាមួយគ្នានេះ កម្មវិធីនេះក៏មានការចូលរួមគាំទ្រអនុវត្តពីក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗ រួមមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងផែនការ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងមហាផ្ទៃ, ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងធម្មការ និងសាសនា, ក្រសួងកិច្ចការនារី, និងក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

រូបភាពទី៤៖ ក្របខណ្ឌអភិបាលកិច្ច នៃកម្មវិធី




តួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធមានដូចខាងក្រោម៖

### ៧.១. ក្រុមប្រឹក្សាជាតិគាំពារសង្គម

ដោយមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ.)ជាសេនាធិការ, ក្រុមប្រឹក្សាជាតិគាំពារសង្គម មានតួនាទី និងភារកិច្ច៖

- សម្របសម្រួលកិច្ចសហការរវាងក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ
- ផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងការអនុវត្តកម្មវិធី

- ពិនិត្យ និងសម្រេចលើផែនការពង្រីកវិសាលភាពប្រចាំឆ្នាំ
- ធានាឱ្យបានរំហូរថវិកាសម្រាប់អនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព
- ពិនិត្យតាមដាន វាយតម្លៃ និងផ្តល់យោបល់លើវឌ្ឍនភាពនៃការអនុវត្តកម្មវិធី
- ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- កំណត់កាលបរិច្ឆេទនៃដាក់ឱ្យអនុវត្តកម្មវិធី និង
- រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តកម្មវិធីជូនរាជរដ្ឋាភិបាល។

### ៧.២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ពិនិត្យ ផ្តល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់អនុវត្តកម្មវិធី
- វិភាជថវិកាសម្រាប់ការអនុវត្តកម្មវិធី
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍អនុវត្តថវិកា និងសមិទ្ធកម្មរបស់កម្មវិធី និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

### ៧.៣. ក្រសួងផែនការ

- អនុវត្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំ និងធ្វើបច្ចុប្បន្នភាពទិន្នន័យជាប្រចាំ
- ផ្តល់ទិន្នន័យគ្រួសារក្រីក្រ សម្រាប់ការអនុវត្តកម្មវិធី តាមរយៈសន្ទានកម្ម នៃកម្មវិធីកុំព្យូទ័រ (API) និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

### ៧.៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- កំណត់យុទ្ធសាស្ត្រសម្រាប់ការអនុវត្តកម្មវិធី
- តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេស
- ណែនាំវិធានការដោះស្រាយពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេស
- ពិនិត្យ ផ្តល់យោបល់ និងសម្រេចលើផែនការអភិវឌ្ឍន៍ ផែនការថវិកា របាយការណ៍ហិរញ្ញវត្ថុ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត និង
- សហការ និងផ្តល់ការគាំទ្រដល់ការអនុវត្តកម្មវិធីតាមការចំបាច់។

### ៧.៥. ក្រសួងមហាផ្ទៃ

- សហការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការអនុវត្តកម្មវិធី
- ពង្រឹងការអនុវត្តតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តកម្មវិធី

- រៀបចំ និងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា តាមការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកម្មវិធី និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៧.៦. ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

- សម្របសម្រួល តាមដាន វាយតម្លៃ និងផ្តល់យោបល់លើការរៀបចំ ការអនុវត្តកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្រនានា ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ និងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ និងវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និង
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

## ៧.៧. ក្រសួងអប់រំ យុវជន និងកីឡា

- សហការ និងផ្តល់ធាតុចូលក្នុងការរៀបចំវគ្គបណ្តុះបណ្តាលជូនគ្រួសារគោលដៅ តាមការចាំបាច់
- សហការ សម្របសម្រួល និងគាំទ្រដល់ការជំរុញការផ្សារភ្ជាប់រវាងកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ និងកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ តាមទីតាំងគោលដៅ និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

## ៧.៨. ក្រសួងធម្មការ និងសាសនា

- សហការ និងគាំទ្រដល់ការអនុវត្តកម្មវិធី តាមរយៈការជំរុញការផ្សព្វផ្សាយពីតួអង្គសាសនា
- សហការ និងផ្តល់ធាតុចូលក្នុងការរៀបចំវគ្គបណ្តុះបណ្តាលជូនគ្រួសារគោលដៅ តាមការចាំបាច់
- បំផុសចលនាចូលរួម និងគាំទ្រការអនុវត្តកម្មវិធីពីអារាមសាសនានៅតាមទីតាំងគោលដៅ និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

## ៧.៩. ក្រសួងកិច្ចការនារី

- សហការជាមួយក្រសួង-ស្ថាប័នក្នុងការអនុវត្តកម្មវិធីនេះឱ្យឆ្លើយតបនឹងយេនឌ័រ
- ផ្តល់ការគាំទ្រដល់មន្ទីរកិច្ចការនារី និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីពាក់ព័ន្ធនឹងយេនឌ័រ

- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

### ៧.១០. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ជានាឱ្យមានមន្ត្រីកសិកម្មដែលមានបទពិសោធននៅតាមទីតាំងគោលដៅនៃកម្មវិធី ដើម្បីគាំទ្រការអនុវត្ត
- ផ្តល់ការគាំទ្រ និងរៀបចំសហគមន៍កសិកម្មនៅទីតាំងគោលដៅនៃកម្មវិធី និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

### ៧.១១. មូលនិធិជាតិជំនួយសង្គម៖ ប្រតិបត្តិករបើកផ្តល់សាច់ប្រាក់

- ដឹកនាំ និងគ្រប់គ្រងការបើកផ្តល់សាច់ប្រាក់ជូនគ្រួសារទទួលផល ដោយសហការជាមួយភ្នាក់ងារបើកផ្តល់
- រៀបចំឯកសារគតិយុត្ត និងឯកសារពាក់ព័ន្ធតាមការចាំបាច់ សម្រាប់គ្រប់គ្រង និងចាត់ចែងការបើកផ្តល់សាច់ប្រាក់ឱ្យមានប្រសិទ្ធភាព
- រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានសម្រាប់ការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធីដល់មុខសញ្ញានៅតាមទីតាំងភូមិសាស្ត្រគោលដៅ និងដល់ភាគីពាក់ព័ន្ធ
- សហការ និងសម្របសម្រួលជាមួយរដ្ឋបាលរាជធានី ខេត្តគោលដៅ និងភាគីពាក់ព័ន្ធ ដើម្បីអនុវត្តកម្មវិធីឱ្យបានរលូន
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ និងដំណើរការកម្មវិធី
- តាមដានវឌ្ឍនភាពនៃការប្រើប្រាស់សាច់ប្រាក់ឧបត្ថម្ភរបស់គ្រួសារទទួលផល ព្រមទាំងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ និង
- រាយការណ៍ជាប្រចាំជូន អ.ក.គ. និងស្ថាប័នពាក់ព័ន្ធអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

### ៧.១២. រដ្ឋបាលថ្នាក់រាជធានី-ខេត្តគោលដៅ៖ ប្រតិបត្តិករដឹកនាំការអនុវត្តកម្មវិធីនៅថ្នាក់ក្រោមជាតិ

- ដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីជារួមនៅរដ្ឋបាលរាជធានី ខេត្តសាមី
- រៀបចំលិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ និងយន្តការដឹកនាំតាមការចាំបាច់ សម្រាប់គ្រប់គ្រង និងចាត់ចែងការអនុវត្តកម្មវិធីឱ្យមានប្រសិទ្ធភាព
- សហការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការនៃកម្មវិធីនៅថ្នាក់ក្រោមជាតិ

- ពិនិត្យ និងតាមដានការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធីដល់មុខសញ្ញានៅតាមទីតាំងភូមិសាស្ត្រគោលដៅ និងជូនដល់ភាគីពាក់ព័ន្ធ
- ផ្តល់ទិន្នន័យគ្រួសារមានបណ្ណសមធម៌ដែលបានជ្រើសរើសមកមូលនិធិជាតិជំនួយសង្គម
- រៀបចំឧបករណ៍ និងកម្មវិធីបណ្តុះបណ្តាល និងបង្វឹកជូនគ្រួសារទទួលផល ដោយសហការជាមួយភាគីពាក់ព័ន្ធ
- តាមដានការផ្តល់វគ្គបណ្តុះបណ្តាល និងការបង្វឹក ដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- តាមដានដំណើរការពិនិត្យ និងជំរុញការប្រើប្រាស់ប្រាក់ដើមទុនសម្រាប់ទ្រព្យសកម្មរបស់គ្រួសារទទួលផល ដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យបានការប្រើប្រាស់ប្រាក់ដើមទុនចំគោលដៅ
- តាមដានការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ អនុវត្តដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- សម្របសម្រួល និងផ្តល់សេវាតភ្ជាប់ទៅកាន់កម្មវិធី និងរបបក្នុងប្រព័ន្ធគាំពារសង្គម និងសេវាបំពេញបន្ថែមនានា ព្រមទាំងឱកាសទីផ្សារ
- ពិនិត្យ និងតាមដានការអនុវត្តកម្មវិធី ព្រមទាំងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីនៅរដ្ឋបាលរាជធានី ខេត្តសាមី និង
- រៀបចំរបាយការណ៍ជាប្រចាំជូន អ.ក.គ. និងភាគីពាក់ព័ន្ធ អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

## ៧.១៣. សាខាមូលនិធិជាតិជំនួយសង្គម ថ្នាក់រាជធានី-ខេត្តគោលដៅ

- គាំទ្រការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ និងកញ្ចប់ប្រាក់ដើមទុនសម្រាប់ទ្រព្យសកម្មជូនគ្រួសារទទួលផល
- ចូលរួមដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការបើកផ្តល់សាច់ប្រាក់
- ចូលរួមក្នុងដំណើរការប្រមូលទិន្នន័យ, ដោះស្រាយបញ្ហាប្រឈម, ព្រមទាំងការតាមដាន និងវាយតម្លៃនៃកម្មវិធី និង
- ផ្តល់ការគាំទ្រផ្សេងៗសម្រាប់អនុវត្តកម្មវិធី តាមការចាំបាច់។

## ៧.១៤. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- ផ្តល់ការគាំទ្រសម្រាប់ការផ្តល់វគ្គបណ្តុះបណ្តាល និងបង្វឹកអំពីមុខរបរ និងបំណិនជីវិត ជូនគ្រួសារទទួលផល
- ផ្តល់ការគាំទ្រអនុវត្តយន្តការបញ្ជូនបន្តទៅកាន់អត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម និងសេវាសង្គមនានា
- ផ្តល់ការគាំទ្រពាក់ព័ន្ធនឹងសេវាបច្ចេកទេសកសិកម្មជូនរដ្ឋបាលថ្នាក់ក្រុង-ស្រុក និងឃុំ-សង្កាត់ ដើម្បីពង្រឹងសមត្ថភាពក្នុងការអនុវត្តកម្មវិធី និង

- ចូលរួមក្នុងដំណើរការប្រមូលទិន្នន័យ, ដោះស្រាយបញ្ហាប្រឈម, ព្រមទាំងការតាមដាន និងវាយតម្លៃនៃកម្មវិធី និង
- ផ្តល់ការគាំទ្រចាំបាច់ផ្សេងៗ ដើម្បីធានាការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធិភាពនៅថ្នាក់ក្រោមជាតិ។

### ៧.១៥. មន្ទីរផែនការ

- ផ្តល់ការគាំទ្រពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ តាមការស្នើសុំ
- ចូលរួមដោះស្រាយបញ្ហាប្រឈមរបស់គ្រួសារទទួលផលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមក្នុងដំណើរការប្រមូលទិន្នន័យ ព្រមទាំងការតាមដាន និងវាយតម្លៃនៃកម្មវិធី និង
- ផ្តល់ការគាំទ្រចាំបាច់ផ្សេងៗ ដើម្បីធានាការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធិភាពនៅថ្នាក់ក្រោមជាតិ។

### ៧.១៦. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ផ្តល់ការគាំទ្រសម្រាប់ការផ្តល់វគ្គបណ្តុះបណ្តាល និងបង្ហឹកអំពីមុខរបរ និងបំណិនជីវិត ជូនគ្រួសារទទួលផល
- ផ្តល់ការគាំទ្របច្ចេកទេសជូនរដ្ឋបាលថ្នាក់ក្រុង-ស្រុក និងឃុំ-សង្កាត់ដើម្បីពង្រឹងសមត្ថភាពក្នុងការអនុវត្តកម្មវិធី
- សម្របសម្រួលការគាំទ្រពីមន្ត្រីបច្ចេកទេសកសិកម្មនៅតាមថ្នាក់ឃុំ-សង្កាត់សម្រាប់អនុវត្តកម្មវិធី
- ចូលរួមក្នុងដំណើរការប្រមូលទិន្នន័យ, ដោះស្រាយបញ្ហាប្រឈម, ព្រមទាំងការតាមដាន និងវាយតម្លៃនៃកម្មវិធី និង
- ផ្តល់ការគាំទ្រចាំបាច់ផ្សេងៗ ដើម្បីធានាការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធិភាពនៅថ្នាក់ក្រោមជាតិ។

### ៧.១៧. មន្ទីរកិច្ចការនារី

- ផ្តល់ការគាំទ្រសម្រាប់ការផ្តល់វគ្គបណ្តុះបណ្តាល និងបង្ហឹកអំពីការបង្កើតមុខរបរ និងបំណិនជីវិតពាក់ព័ន្ធនឹងយេនឌ័រជូនគ្រួសារទទួលផល
- ផ្តល់ការគាំទ្រក្នុងការអនុវត្តយន្តការបញ្ជូនបន្តទៅកាន់អត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម និងសេវាសង្គមនានាៗ
- ចូលរួមក្នុងដំណើរការប្រមូលទិន្នន័យ, ដោះស្រាយបញ្ហាប្រឈម, ព្រមទាំងការតាមដាន និងវាយតម្លៃនៃកម្មវិធី និង
- ផ្តល់ការគាំទ្រចាំបាច់ផ្សេងៗ ដើម្បីធានាការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធិភាពនៅថ្នាក់ក្រោមជាតិ។

### ៧.១៨. រដ្ឋបាលថ្នាក់ក្រុង-ស្រុក-ខណ្ឌគោលដៅ

- ដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីក្រោមដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធីជូនគ្រួសារគោលដៅ
- កៀរគរ និងចុះឈ្មោះគ្រួសារគោលដៅក្នុងកម្មវិធី
- ផ្តល់ការបណ្តុះបណ្តាល និងបង្វឹកដល់គ្រួសារទទួលផល ដោយសម្របសម្រួល និងមានការគាំទ្រពីភាគីពាក់ព័ន្ធ
- រៀបចំយន្តការជ្រើសរើស និងគ្រប់គ្រងការចុះសួរសុខទុក្ខ និងបង្វឹកតាមផ្ទះ
- តាមដាន និងជំរុញការប្រើប្រាស់ប្រាក់ដើមទុនសម្រាប់ទ្រព្យសកម្មរបស់គ្រួសារទទួលផល ដើម្បីធានាឱ្យបានការប្រើប្រាស់ចំគោលដៅ
- ពិនិត្យ និងតាមដានការអនុវត្តកម្មវិធី ព្រមទាំងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- រៀបចំរបាយការណ៍ជូនរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

### ៧.១៩. រដ្ឋបាលថ្នាក់ឃុំ-សង្កាត់គោលដៅ

- គាំទ្រដំណើរការផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹង កៀរគរ និងចុះឈ្មោះគ្រួសារគោលដៅក្នុងកម្មវិធី
- គាំទ្រដំណើរការផ្តល់វគ្គការបណ្តុះបណ្តាល និងការបង្វឹកជូនគ្រួសារទទួលផល
- គាំទ្រដំណើរការចុះសួរសុខទុក្ខ និងបង្វឹកតាមផ្ទះ ព្រមទាំងតាមដានវឌ្ឍភាពគ្រួសារទទួលផល
- ចូលរួមកម្មវិធីពង្រឹងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីដែលផ្តល់ដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង
- ចូលរួមពិនិត្យ និងតាមដានការអនុវត្តកម្មវិធី ព្រមទាំងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីក្នុងដែលសមត្ថកិច្ចរបស់ខ្លួន និង
- រៀបចំរបាយការណ៍ជាប្រចាំជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់ខ្លួន អំពីវឌ្ឍភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

## ៨. សកម្មភាពអន្តរកាល និងការត្រៀមខ្លួន

### ៨.១. ការរៀបចំកម្មវិធី និងក្របខណ្ឌស្ថាប័ន

ផ្អែកលើបទពិសោធនៃការអនុវត្តគម្រោងសាកល្បងកិច្ចគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ, ការរៀបចំបង្កើតនូវឯកសារគតិយុត្ត, សៀវភៅណែនាំប្រតិបត្តិគោលកម្មវិធី និងក្របខណ្ឌស្ថាប័នជាកិច្ចការចាំបាច់ដើម្បីធានាបាននូវការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។ សកម្មភាពជាអាទិភាពដែលត្រូវតែអនុវត្តដោយភាគីពាក់ព័ន្ធសំខាន់ៗ មានដូចខាងក្រោម៖

- **អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម៖** សម្របសម្រួល និងរៀបចំអនុក្រឹត្យ និងសេចក្ដីសម្រេច ដើម្បីដាក់ឱ្យអនុវត្តកម្មវិធី
- **មូលនិធិជាតិជំនួយសង្គម៖** រៀបចំឯកសារគតិយុត្តពាក់ព័ន្ធ និងសៀវភៅណែនាំប្រតិបត្តិគោលស្តីពីការបើកផ្តល់សាច់ប្រាក់ ព្រមទាំងរៀបចំប្រព័ន្ធបើកផ្តល់សម្រាប់កម្មវិធី
- **រដ្ឋបាលថ្នាក់រាជធានី ខេត្ត៖**
    - រៀបចំយន្តការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីនៅកម្រិតថ្នាក់ក្រោមជាតិរបស់ខ្លួន និងរៀបចំលិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ
    - រៀបចំឯកសារ និងសៀវភៅណែនាំប្រតិបត្តិចាំបាច់សម្រាប់ការអនុវត្តកម្មវិធី រួមមាន៖
        - សៀវភៅណែនាំប្រតិបត្តិគោល និងស្តង់ដាការបណ្តុះបណ្តាល និងបង្វឹករបស់កម្មវិធី
        - និតិវិធីប្រតិបត្តិស្តង់ដារគោលសម្រាប់ការជ្រើសរើស បណ្តុះបណ្តាល និងគ្រប់គ្រងអ្នកស្ម័គ្រចិត្តក្នុងសហគមន៍, និតិវិធីប្រតិបត្តិស្តង់ដារគោលសម្រាប់ការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ
        - ក្រុមសម្រាប់អនុវត្តការចុះសួរសុខទុក្ខតាមខ្នងផ្ទះ ដោយណែនាំអំពីរបៀប និងលំដាប់លំដោយក្នុងការបង្វឹក និងស្តង់ដារគំរូសម្រាប់ការវាយតម្លៃ ការចុះតាមខ្នងផ្ទះ និងការតាមដានករណី និងវឌ្ឍនភាពគ្រួសារ
        - រៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធី និង
        - រៀបចំផែនការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធី។

## ៨.២. អន្តរាគមន៍ផ្សេងទៀត

### ៨.២.១.យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

លក្ខខណ្ឌជ្រើសរើសគ្រួសារទទួលផលក្រោមក្របខណ្ឌកម្មវិធីគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ផ្តោតសំខាន់លើស្ថានភាពនៃភាពក្រីក្រគ្រួសារ ដូចគ្នាផងដែរនឹងកម្មវិធីជំនួយសង្គមផ្សេងៗដែលបាន និងកំពុងអនុវត្ត ហើយយន្តការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានតួនាទីសំខាន់ក្នុងផ្តល់ទិន្នន័យគ្រួសារគោលដៅសម្រាប់ការអនុវត្តកម្មវិធីនេះ។ ក្នុងន័យនេះ ការបន្តពង្រឹងយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាកិច្ចការចាំបាច់សម្រាប់ការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ។

### ៨.២.២. ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស

ដំណើរការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ទាមទារឱ្យមានការរៀបចំផែនការ និងការអនុវត្តការងារសំខាន់ៗ ដូចជាការបណ្តុះបណ្តាល ការសួរសុខទុក្ខ និងការបង្វឹកតាមខ្នងផ្ទះ និងការតាមដានវឌ្ឍនភាពគ្រួសារ ព្រមទាំងកិច្ចការសំខាន់ៗដទៃទៀត ដែលមានលក្ខណៈស្មុគស្មាញជៀបនឹងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដោយមិនភ្ជាប់លក្ខខណ្ឌ។ ភាពជោគជ័យនៃការអនុវត្តកម្មវិធីនេះពឹងផ្អែកជាចម្បងលើសមត្ថភាពរបស់ប្រតិបត្តិករថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ មូលនិធិជាតិជំនួយសង្គម និងរដ្ឋបាលថ្នាក់រាជធានី ខេត្តគោលដៅ ព្រមទាំងភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិផ្សេងៗទៀតចាំបាច់ត្រូវបន្តពង្រឹងសមត្ថភាព និងធនធានមនុស្សជាប្រចាំ សម្រាប់ការអនុវត្តកម្មវិធី ដើម្បីឱ្យសមត្ថភាពការងារ និងលទ្ធផលការអនុវត្តការងារមានភាពប្រសើរឡើង។

### ៨.២.៣. ការកៀរគរធនធាន

ថវិកាជាតិ ជាប្រភពចម្បងសម្រាប់ការអនុវត្តកម្មវិធីគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ។ ដើម្បីធានាបាននូវភាពទ្រទ្រង់បាននៃថវិកាជាតិ និងនិរន្តរភាពនៃកម្មវិធី, កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ នឹងត្រូវដាក់ឱ្យដំណើរការជាជំហានៗស្របតាមគោលការណ៍អនុវត្ត។ ទន្ទឹមនេះ ការស្វែងរកថវិកាពីប្រភពស្របច្បាប់ដទៃទៀត ជាកិច្ចការចាំបាច់ រួមទាំងប្រភពថវិកាពីដៃគូអភិវឌ្ឍន៍នានា និងប្រភពពីកិច្ចសហការភាពជាដៃគូនៃគំនិតផ្តួចផ្តើមនៅកម្រិតតំបន់ និងសកល ដូចជាភាពជាដៃគូក្នុងកិច្ចការប្រែប្រួលអាកាសធាតុ។

## ៩. វដ្តប្រតិបត្តិការ និងជំហាននៃកម្មវិធី

វដ្តនៃប្រតិបត្តិការ សំដៅដល់ចន្លោះរយៈពេលដែលគ្រួសារទទួលផលចាប់ផ្តើមមុនពេលចូលក្នុងកម្មវិធី និងចាកចេញពីកម្មវិធី។ វដ្តនៃប្រតិបត្តិការមាន ៦ ជំហានសំខាន់ៗ រួមមានការកំណត់ទីតាំងគោលដៅ និងការចុះឈ្មោះក្រុមគោលដៅ, ការអនុវត្តលក្ខខណ្ឌ អនុលោមភាព និងការបើកផ្តល់ប្រាក់ឧបត្ថម្ភ, ការចុះសួរសុខទុក្ខ បង្វឹកតាមផ្ទះ និងតាមដានវឌ្ឍភាពគ្រួសារ, ការផ្ទៀងផ្ទាត់ហិរញ្ញវត្ថុ និងការរាយការណ៍, ការដោះស្រាយបណ្តឹងតវ៉ា, និងការតាមដាន និងការវាយតម្លៃ ដូចបង្ហាញនៅក្នុងរូបភាពទី ៥។

រូបភាពទី ៥៖ វដ្តប្រតិបត្តិការ




## ៩.១. ការកំណត់ទីតាំងគោលដៅ និងការចុះឈ្មោះក្រុមគោលដៅ

ការកំណត់ទីតាំងភូមិសាស្ត្រ ដូចជារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌគោលដៅ ព្រមទាំងចំនួនគ្រួសារ សម្រាប់ពង្រីកវិសាលភាពការអនុវត្តកម្មវិធី ត្រូវបានរៀបចំជាមុនដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានក្នុងផ្នែក ៥.២.១ ដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលត្រូវបានជ្រើសរើសត្រូវធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធី ព្រមទាំងបើកការចុះឈ្មោះក្រុមគោលដៅចូលកម្មវិធី។ គ្រួសារមានបណ្ណសមធម៌ ក្រ១ ឬក្រ២ ទៅសាលាក្រុង ស្រុក ខណ្ឌ ដើម្បីចុះឈ្មោះចូលក្នុងកម្មវិធី ដោយប្រើប្រាស់ប្រព័ន្ធឌីជីថល។ បន្ទាប់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការអង្កេតរហ័សដើម្បីវាយតម្លៃលទ្ធភាពពលកម្មរបស់គ្រួសារធៀបនឹងលក្ខខណ្ឌចុះឈ្មោះ ដូចមានក្នុងផ្នែក ៥.២.២ ព្រមទាំងប្រមូលព័ត៌មានចាំបាច់ផ្សេងទៀត។ ជាជំហានបន្ទាប់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបញ្ជីគ្រួសារដែលត្រូវបានជ្រើសរើស ស្របតាមកូតាកំណត់ និងដាក់ជូនរដ្ឋបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងសម្រេច។ រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ញើបញ្ជីគ្រួសារដែលត្រូវបានជ្រើសរើសជូនអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ.) និងមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.)។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់គ្រួសារដែលត្រូវបានជ្រើសរើសចូលរួមក្នុងកម្មវិធី។ ដំណើរការកំណត់ទីតាំងគោលដៅ និងការចុះឈ្មោះក្រុមគោលដៅមានបង្ហាញក្នុងរូបភាពទី ៦ ខាងក្រោម។

រូបភាពទី ៦៖ ការកំណត់ទីតាំងគោលដៅ និងការចុះឈ្មោះក្រុមគោលដៅ




## ៩.២. លក្ខខណ្ឌ អនុលោមភាព និងការបើកផ្តល់សាច់ប្រាក់

បន្ទាប់ពីបានចូលរួមក្នុងកម្មវិធី គ្រួសារទទួលផលតម្រូវឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការអនុលោមតាមកម្មវិធី ហើយនៅពេលកម្មវិធីបានចាប់ផ្តើម គ្រួសារត្រូវចូលរួមគ្រប់វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំ និងការបង្វឹក និងការផ្តល់ប្រឹក្សាយោបល់ ដូចបានកំណត់។ គ្រួសារត្រូវបំពេញលក្ខខណ្ឌ ដូចមានកំណត់ក្នុងតារាងទី១ ដើម្បីទទួលបានការឧបត្ថម្ភប្រាក់សម្រាប់ការបណ្តុះបណ្តាល និងប្រាក់ដើមទុនសម្រាប់ទិញទ្រព្យសកម្ម។

គ្រួសារដែលបានជ្រើសរើសត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងប្រព័ន្ធបើកផ្តល់របស់ ម.ជ.ជ.។ ការបើកផ្តល់សាច់ប្រាក់នឹងប្រើប្រាស់ប្រព័ន្ធឌីជីថល តាមរយៈប្រព័ន្ធដែលមានស្រាប់របស់ ម.ជ.ជ. ផ្ទេរទៅគណនីធនាគារគ្រួសារសម្រាប់កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ ខណៈដែលសាច់ប្រាក់ឧបត្ថម្ភសម្រាប់ចូលរួមការបណ្តុះបណ្តាលត្រូវបើកផ្តល់រៀងរាល់ចុងខែនីមួយៗ បន្ទាប់ពីលក្ខខណ្ឌត្រូវបានបំពេញ, ការបើកផ្តល់ប្រាក់ដើមទុនសម្រាប់ទ្រព្យសកម្ម អាចត្រូវធ្វើឡើងដោយឡែកតាមកាលវិភាគដែលបានកំណត់។ គ្រូបង្គោលផ្តល់វគ្គបណ្តុះបណ្តាលពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ចូលព័ត៌មានវត្តមានរបស់គ្រួសារទទួលផលទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដោយប្រើប្រាស់ថាប្លេត/ទូរសព្ទឆ្លាតវៃ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ធ្វើការបញ្ជាក់អំពីព័ត៌មានវត្តមាននេះនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៃកម្មវិធីជាតិគាំពារសង្គម ដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ដើម្បីបញ្ជូនមក ម.ជ.ជ. សម្រាប់ធ្វើការបើកផ្តល់សាច់ប្រាក់។

រូបភាពទី ៧៖ លក្ខខណ្ឌ និងដំណើរការបើកផ្ដល់សាច់ប្រាក់




## ៩.៣. ការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ

ការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ ត្រូវដឹកនាំ និងគ្រប់គ្រងដោយរដ្ឋបាលរដ្ឋក្រុង ស្រុក ខណ្ឌ និងអនុវត្តផ្ទាល់ប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យតាមបែបឌីជីថល។ ការចុះសួរសុខទុក្ខ និងបង្វឹក ត្រូវធ្វើឡើងជាប្រចាំខែតាមខ្នងផ្ទះ ដើម្បីធានាឱ្យបានដំណើរការនៃកម្មវិធី ព្រមទាំងតាមដានវឌ្ឍនភាពរបស់គ្រួសារ ប្រៀបធៀបលទ្ធផលនឹងផែនការអាជីវកម្ម ដោះស្រាយបញ្ហាប្រឈមនានា និងផ្ដល់ការតម្រង់ទិស គាំទ្រ និងលើកទឹកចិត្តបន្ថែមដល់គ្រួសារក្នុងការកសាងជំនាញទន់ ការផ្លាស់ប្ដូរឥរិយាបថ និងការធ្វើវិនិយោគរបស់គ្រួសារ។ ទិន្នន័យទាំងនេះនឹងត្រូវប្រើប្រាស់ជាធាតុចូលសម្រាប់កែសម្រួលការអនុវត្តនៃកម្មវិធី ព្រមទាំងជាធាតុចូលសម្រាប់អនុវត្តយន្តការបញ្ជូនគ្រួសារបន្តទៅកាន់សេវាបំពេញបន្ថែមនានា (ក្នុងអំឡុងពេល និងក្រោយពេលបញ្ចប់នៃកម្មវិធី)។

ជាមួយគ្នានេះ កម្មវិធីនឹងប្រើប្រាស់បណ្ដុំសូចនាករពហុវិមាត្រដែលអនុវត្តជាសកល (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី ២) ដើម្បីវាយតម្លៃអំពីស្ថានភាពវឌ្ឍនភាព និងគន្លងត្រឹមត្រូវរបស់គ្រួសារក្នុងការលើកកម្ពស់ជីវភាព និងឈានចាកចេញពីភាពក្រីក្រ។ សូមពិនិត្យមើលតារាងទី២ ខាងក្រោម សម្រាប់កាលវិភាគលម្អិតនៃការវាយតម្លៃ៖

តារាងទី២៖ កាលវិភាគសម្រាប់ការវាយតម្លៃ

| ល.រ | ការវាយតម្លៃ | កាលវិភាគ |
|---|---|---|
| ១ | ការវាយតម្លៃដើមគ្រា | ខែទី១ ដល់ ខែទី៣ |
| ២ | ការវាយតម្លៃពាក់កណ្តាលគ្រា | ខែទី១២ |
| ៣ | ការវាយតម្លៃចុងគ្រា | ខែទី២៤ |

ការវាយតម្លៃដោយប្រើប្រាស់បណ្តុំសូចនាករពហុវិមាត្រដែលអនុវត្តជាសកល គឺដាច់ដោយឡែកពីស្ថានភាពបណ្ណសមធម៌របស់គ្រួសារ ដែលនេះមានន័យថា ទោះបីជាគ្រួសារគោលដៅត្រូវបានវាយតម្លៃថាបានអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រដោយជោគជ័យ, គ្រួសារទាំងនោះនៅបន្តមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងកម្មវិធីជំនួយសង្គមផ្សេងៗទៀត រហូតដល់ស្ថានភាពបណ្ណសមធម៌មានការប្រែប្រួល។

## ៩.៤. ការផ្ទៀងផ្ទាត់ហិរញ្ញវត្ថុ និងការរាយការណ៍

គ្រប់ប្រតិបត្តិករអនុវត្តថវិកាសម្រាប់កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្ររួមមាន មូលនិធិជាតិជំនួយសង្គម រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបំពេញតួនាទីផ្ទៀងផ្ទាត់ហិរញ្ញវត្ថុ តាមតួនាទី ភារកិច្ចរបស់ខ្លួន និងតាមការកំណត់របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ត្រូវបំពេញតួនាទីរាយការណ៍ ទៅតាមតួនាទី ភារកិច្ចរបស់ខ្លួន និងតាមការកំណត់របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ៩.៥. យន្តការដោះស្រាយបណ្តឹងតវ៉ា

### ៩.៥.១. បញ្ហាបច្ចេកទេសប្រចាំថ្ងៃ

រដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលបន្ទុកដោះស្រាយបញ្ហាបច្ចេកទេសប្រចាំថ្ងៃជូនគ្រួសារទទួលផលទៅតាមស្ថានភាពជាក់ស្តែង ខណៈមូលនិធិជាតិជំនួយសង្គម ដែលមានសាខារាជធានី ខេត្ត ចូលរួមទទួលបន្ទុកដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភដោយប្រើប្រាស់យន្តការកម្មវិធីជាតិជំនួយសង្គមដែលមានស្រាប់។

### ៩.៥.២. យន្តការបណ្តឹងតវ៉ា និងវិវាទ

កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ប្រើប្រាស់យន្តការបណ្តឹងតវ៉ា និងវិវាទ ដែលមានលក្ខណៈងាយស្រួលសម្រាប់ការប្រើប្រាស់ ដោយរក្សាអនាមិកភាពក្នុងករណីចាំបាច់។

ការដោះស្រាយបណ្ដឹង ត្រូវអនុវត្តដោយស្មើភាព យុត្តិធម៌ តម្លាភាព គណនេយ្យភាព និងទាន់ពេល ក្នុងនោះ ការដាក់ពាក្យបណ្ដឹងមានច្រើនសណ្ឋាន រួមមានដាក់ពាក្យផ្ទាល់ទៅសាលាឃុំ សង្កាត់, សាលាក្រុង ស្រុក ខណ្ឌ, សាខាមូលនិធិជាតិជំនួយសង្គម, មូលនិធិជាតិជំនួយសង្គម, ឬអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ ការទាក់ទងដោយផ្ទាល់មាត់ពាក់ព័ន្ធនឹងការឧបត្ថម្ភសាច់ប្រាក់ក៏អាចធ្វើឡើងតាមទូរសព្ទហៅទៅលេខទូរសព្ទទាន់ហេតុការណ៍ដែលគ្រប់គ្រងដោយ ម.ជ.ជ.។ បណ្ដឹងអនាមិក និងបណ្ដឹងដាក់លាក់ទាំងអស់ត្រូវបានកត់ត្រា និងគ្រប់គ្រង តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។

ក្នុងករណីបណ្ដឹងតវ៉ា និងវិវាទ ត្រូវបានដាក់ពាក្យនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ, រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវព្យាយាមដោះស្រាយ។ ករណីមិនសះជា បណ្ដឹងនឹងត្រូវបញ្ជូនបន្តទៅរដ្ឋបាលរាជធានី ខេត្ត និងមូលនិធិជាតិជំនួយសង្គម និងចុងក្រោយទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

មន្ត្រីអនុវត្តកម្មវិធីដែលប្រព្រឹត្តមិនប្រក្រតី ត្រូវទទួលទណ្ឌកម្មខាងវិន័យ និងទោស អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ៩.៦. ការតាមដាន និងការវាយតម្លៃ

### ៩.៦.១. ការតាមដាន

ការតាមដានកម្មវិធី ត្រូវអនុវត្តជាប្រចាំ ដើម្បីគាំទ្រដំណើរការអនុវត្តកម្មវិធីឱ្យបានគ្រប់ជ្រុងជ្រោយ និងរលូន។ ប្រតិបត្តិករអនុវត្តកម្មវិធី រួមមានមូលនិធិជាតិជំនួយសង្គម និងរដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចតាមដានការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ នៅកម្រិតកម្មវិធីជាប្រចាំ ក្នុងគោលលបំណង៖

- ពិនិត្យវឌ្ឍនភាពរបស់កម្មវិធី
- ពិនិត្យការអនុវត្តកម្មវិធី និងការបើកផ្ដល់សាច់ប្រាក់ ដើម្បីធានាថាដំណើរការកម្មវិធីប្រព្រឹត្តទៅដោយរលូន
- កំណត់រកភាពរាំងស្ទះ និងបញ្ហាប្រឈមក្នុងការអនុវត្ត និងធ្វើការដោះស្រាយឱ្យបានទាន់ពេល
- ធានាឱ្យបាននូវគណនេយ្យភាព និងតម្លាភាពចំពោះអ្នកពាក់ព័ន្ធទាំងអស់។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម អាចចាត់មន្ត្រីពាក់ព័ន្ធចុះត្រួតពិនិត្យ និងតាមដានកម្មវិធី ដោយមានកិច្ចសហការពីប្រតិបត្តិករអនុវត្តកម្មវិធី និងភាគីពាក់ព័ន្ធ។

### ៩.៦.២ ការវាយតម្លៃ

ការវាយតម្លៃអំពីដំណើរការ និងកម្មវិបាកនៃកម្មវិធី ត្រូវដឹកនាំដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ការវាយតម្លៃកម្មវិបាក ឬអង្កេតអំពីលទ្ធផលនៃកម្មវិធី អាចត្រូវបានរៀបចំឡើងប្រចាំឆ្នាំ និង ២ ឆ្នាំ ក្រោយពេលកម្មវិធីត្រូវបានបិទបញ្ចប់នៅតាមទីតាំង

ភូមិសាស្ត្រគោលដៅនីមួយៗ ក្នុងគោលបំណងពិនិត្យមើលនូវប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី និងចីរភាពនៃវឌ្ឍភាពរបស់គ្រួសារទទួលផលក្នុងដំណើរចាកចេញពីភាពក្រីក្រជាជំហានៗ ដែលជាធាតុចូលក្នុងការបន្តរៀបចំ ពង្រឹង និងកែលម្អការអនុវត្តគោលនយោបាយ ព្រមទាំងយន្តការនៃកម្មវិធី។

## ១០. ការដាក់ចេញកម្មវិធី និងផែនការពង្រីកវិសាលភាព

ដោយប្រកាន់ខ្ជាប់គោលការណ៍ពង្រីកវិសាលភាពជាជំហានៗ និងផ្អែកលើភាពទ្រទ្រង់បាននៃថវិកាជាតិ, រាជរដ្ឋាភិបាលនឹងដាក់ចេញកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ សម្រាប់រយៈពេល ១០ឆ្នាំ ចាប់ពីឆ្នាំ២០២៥ ដល់ឆ្នាំ២០៣៥ ក្នុងគោលបំណងផ្តល់ការគាំទ្រ និងគ្របដណ្តប់គ្រួសារគោលដៅដែលជាគ្រួសារក្រីក្រ១ និងក្រីក្រ២ ចំនួនប្រមាណ ២០០ ០០០ គ្រួសារ ដូចមានលម្អិតក្នុងតារាងទី៣ ខាងក្រោម។

**តារាងទី ៣៖ ការពង្រីកវិសាលភាពកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាចេញពីភាពក្រីក្រ តាមឆ្នាំ ចាប់ពីឆ្នាំ ២០២៥ ដល់ឆ្នាំ២០៣៥**

| ការពង្រីកវិសាលភាព | ចំនួនគ្រួសារគោលដៅក្នុងវដ្តនៃកម្មវិធី រយៈពេល ២៤ ខែ ឬ២ឆ្នាំ | | ចំនួនគ្រួសារគោលដៅសរុបទទួលបានការគាំទ្រក្នុងឆ្នាំនីមួយៗ |
|---|---|---|---|
| | គ្រួសារគោលដៅចូលថ្មីតាមឆ្នាំ | គ្រួសារគោលដៅបន្តពីឆ្នាំមុន | |
| ២០២៥ | ៥ ០០០ | - | ៥ ០០០ |
| ២០២៦ | ៧ ០០០ | ៥០០០ | ១២ ០០០ |
| ២០២៧ | ៨ ០០០ | ៧ ០០០ | ១៥ ០០០ |
| ២០២៨ | ១០ ០០០ | ៨ ០០០ | ១៨ ០០០ |
| ២០២៩ | ១៥ ០០០ | ១០ ០០០ | ២៥ ០០០ |
| ២០៣០ | ១៥ ០០០ | ១៥ ០០០ | ៣០ ០០០ |
| ២០៣១ | ២៥ ០០០ | ១៥ ០០០ | ៤០ ០០០ |
| ២០៣២ | ២៥ ០០០ | ២៥ ០០០ | ៥០ ០០០ |
| ២០៣៣ | ៣០ ០០០ | ២៥ ០០០ | ៥៥ ០០០ |
| ២០៣៤ | ៣០ ០០០ | ៣០ ០០០ | ៦០ ០០០ |
| ២០៣៥ | ៣០ ០០០ | ៣០ ០០០ | ៦០ ០០០ |
| ២០៣៦ | - | ៣០ ០០០ | ៣០ ០០០ |
| សរុបចំនួនគ្រួសារគោលដៅគ្របដណ្តប់ ២០២៥-២០៣៥ | | ២០០ ០០០ | |

## ១១. សេចក្តីសន្និដ្ឋាន

ក្នុងគោលបំណងផ្តល់ការគាំទ្រដល់គ្រួសារក្រីក្រ បន្ថែមលើសាច់ប្រាក់ឧបត្ថម្ភជំនួយសង្គមដែលមានស្រាប់ ដល់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋក្រីក្រ, ក្រុមប្រឹក្សាជាតិគាំពារសង្គម បានរៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រនេះ ដោយកំណត់អំពីសមាសធាតុ និងនីតិវិធីសំខាន់ៗ រួមមានគោលការណ៍អនុវត្ត, ក្រុមគោលដៅ និងលក្ខខណ្ឌទទួលផល, កញ្ចប់អត្ថប្រយោជន៍, យន្តការស្ថាប័ន, សកម្មភាពអន្តរកាល និងការត្រៀមខ្លួន, និងវដ្តនៃការគ្រប់គ្រងកម្មវិធី, ព្រមទាំងផែនការអនុវត្ត និងពង្រីកវិសាលភាពកម្មវិធី ក្នុងគោលបំណងរៀបចំ និងការដាក់ចេញនូវកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។ បន្ថែមលើអត្ថប្រយោជន៍គាំពារសង្គមនានាដែលមានស្រាប់, កម្មវិធីនេះនឹងជួយកសាងសមត្ថភាព ពង្រឹងភាពធន់ ព្រមទាំងលើកកម្ពស់ជីវភាពរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ តាមរយៈការបណ្តុះបណ្តាល និងការបង្វឹកអំពីការបង្កើតមុខរបរ និងបំណិនជីវិត, សាច់ប្រាក់ឧបត្ថម្ភសម្រាប់ចូលរួមការបណ្តុះបណ្តាល, ការផ្តល់ប្រាក់ដើមទុន, និងការបង្វឹក និងចុះសួរសុខទុក្ខតាមខ្នងផ្ទះដើម្បីអនុញ្ញាតឱ្យគ្រួសារមានសមត្ថភាពចាកចេញពីភាពក្រីក្រជាជំហានៗ និងប្រកបដោយចីរភាព ព្រមទាំងចូលរួមចំណែកក្នុងការលើកកម្ពស់ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

ដើម្បីឈានទៅសម្រេចបានចក្ខុវិស័យ គោលបំណង គោលដៅ និងសកម្មភាពជាអាទិភាព កំណត់ដោយគោលការណ៍ណែនាំនេះ, កិច្ចសហការដ៏រឹងមាំពីគ្រប់ភាគីពាក់ព័ន្ធ ប្រកបដោយភាពបុរេសកម្ម និងភាពជាដៃគូ ទាមទារឱ្យមានជាចាំបាច់ ដើម្បីផ្តល់ឱ្យប្រជាពលរដ្ឋនូវការគាំពារកាន់តែប្រសើរក្រោមប្រព័ន្ធគាំពារសង្គម។

## ឧបសម្ព័ន្ធទី១៖ បញ្ជីទ្រព្យសកម្មសម្រាប់បង្កើតមុខរបរ

| កញ្ចប់ | ប្រាក់ដើមទុន |
|---|---|
| អង្ករ | គ្រាប់ពូជ, ជី, ថ្នាំកំចាត់សត្វល្អិត |
| បន្លែ | គ្រាប់ពូជ, បច្ចេកទេសផ្សាំ, ថ្នាំកំចាត់សត្វល្អិត |
| ផ្សិតចំបើង | ឧបករណ៍សម្រាប់បណ្តុះផ្សិត (មាន ពូជផ្សិត, រោងបណ្តុះផ្សិត, ជី) |
| មាន់ | សត្វមាន់, ចំណីមាន់, រោងចិញ្ចឹមមាន់, វ៉ាក់សាំង ជាដើម |
| ទា | សត្វទា, ចំណីទា, រោងចិញ្ចឹមទា, វ៉ាក់សាំង ជាដើម |
| ចង្រិត | ឧបករណ៍ចិញ្ចឹមចង្រិត |
| ត្រី | ម៉ូទ័រ, សំណាញ់, ខ្សែលួស, ផ្លែសន្ទូច |
| ប្រព័ន្ធស្រោចស្រព | ប្រព័ន្ធបណ្តាញទឹក, អាងស្តុកទឹក, ទុយោ ជាដើម |
| ប្រព័ន្ធជាតសាស្ត្រ | ម៉ាស៊ីនបូមទឹកដែលប្រើប្រាស់ថាមពលព្រះអាទិត្យ |
| ឧបករណ៍ | ឧបករណ៍ចាំបាច់នានាសម្រាប់ការដាំដុះស្រូវ ឬបន្លែ. |

# ឧបសម្ព័ន្ធទី២៖ បណ្តុំសូចនាករពហុវិមាត្រ

| | |
|---|---|
| **សូចនាករគោលគន្លឹះ** | |
| ១ | តម្លៃនៃទ្រព្យសកម្មមានការកើនឡើង យ៉ាងហោចណាស់ទ្វេដង គិតចាប់ពីការចាប់ផ្តើមនៃកម្មវិធី។ |
| ២ | សមាជិកគ្រួសារទាំងអស់ទទួលទានអាហារយ៉ាងហោចណាស់ពីរដងក្នុងមួយថ្ងៃ ហើយការបរិភោគអាហារក្នុងគ្រួសារត្រូវបានពិនិត្យឃើញថាមានកម្រិត 'ទាបប៉ុន្តែអាចទទួលយកបាន' 'Acceptable low’ ផ្អែកតាមការវាស់វែងពិន្ទុការបរិភោគអាហារ។ |
| **សូចនាករបន្ទាប់បន្សំ** | |
| ១ | ចំណាយសម្រាប់ការប្រើប្រាស់សរុបក្នុងគ្រួសារ (រួមទាំងចំណាយហូបចុក) ស្ថិតនៅលើបន្ទាត់នៃភាពក្រីក្របំផុត |
| ២ | ប្រាក់សន្សំសរុបរបស់គ្រួសារ មានយ៉ាងហោចណាស់ស្មើនឹងចំណាយគ្រួសារក្នុងមួយខែ |
| ៣ | ពុំមានប្រាក់កម្ចីសម្រាប់ចំណាយលើតម្រូវការប្រើប្រាស់ក្នុងគ្រួសារ ដែលមិនទាន់បានសង (សម្រាប់ប្រាក់កម្ចីសម្រាប់ការវិនិយោគលើផលិតកម្ម និងការសម្រាកព្យាបាលម្តងម្កាល អាចទទួលយកបាន) |
| ៤ | កុមារគ្រប់អាយុចូលរៀនបឋមសិក្សា និងមធ្យមសិក្សា បានចូលរៀន |
| ៥ | គ្រួសារមានគណនីធនាគារ ឬ Mobile wallet ហើយបន្តប្រើប្រាស់រហូតដល់បញ្ចប់នៃកម្មវិធី |
| ៦ | គ្រួសារបានរាយការណ៍អំពីការប្រើប្រាស់គណនីធនាគារញឹកញ៉ាប់ ដែលឆ្លុះបញ្ចាំងតាមរយៈការដកប្រាក់ចេញពីគណនីផ្ទាល់ខ្លួនពីរដង ឬច្រើនដងក្នុងមួយខែ។ ការប្រើប្រាស់គណនីក៏សំដៅលើប្រតិបត្តិការតាមទូរស័ព្ទនៃផងដែរ |
| ៧ | គ្រួសារបានសន្សំប្រាក់នៅគ្រឹះស្ថានហិរញ្ញវត្ថុក្នុងឆ្នាំកន្លងទៅ។ គ្រឹះស្ថានហិរញ្ញវត្ថុ រួមមានធនាគារ, សហករណ៍, ក្រុមសន្សំ និងផ្តល់ប្រាក់កម្ចីក្រៅផ្លូវការ, និងមីក្រូហិរញ្ញវត្ថុ |
| ៨ | គ្រួសារបានរាយការណ៍អំពីការប្រើប្រាស់សេវាបច្ចេកទេសកសិកម្ម (ដាំដុះ ចិញ្ចឹមសត្វ វារីវប្បកម្ម)។ ការប្រើប្រាស់ញឹកញ៉ាប់ត្រូវបានកំណត់ថាជាការប្រើប្រាស់សេវាបច្ចេកទេសកសិកម្មពីរដង ឬច្រើនដងក្នុងមួយឆ្នាំ |
| ៩ | គ្រួសារបានចំណាយលើការប្រើប្រាស់សេវាបច្ចេកទេសកសិកម្មក្នុងឆ្នាំកន្លងទៅ។ |
| ៧ | សមាជិកគ្រួសារទទួលបានសេវាថែទាំសុខភាព។ ការទទួលបានការថែទាំសុខភាពត្រូវបានវាស់វែង តាមរយៈចំនួននៃការទៅជួបអ្នកផ្តល់សេវាថែទាំសុខភាព (សាធារណៈ និងឯកជន) និងការចំណាយលើការថែទាំសុខភាព (ថ្លៃចំណាយលើការសេវាថែទាំសុខភាព) |
| ៨ | សមាជិកគ្រួសារបានប្រើប្រាស់ប្រភពទឹកនៅគេហដ្ឋានល្អប្រសើរជាងមុន |
| ៩ | សមាជិកគ្រួសារប្រើប្រាស់បង្គន់អនាម័យនៅគេហដ្ឋានល្អប្រសើរជាងមុន |
| ១០ | ស្ថានភាពលំនៅដ្ឋានមានភាពល្អប្រសើរឡើងជាងមុន ចាប់តាំងពីការចាប់ផ្តើមនៃកម្មវិធី (ដោយផ្អែកលើសម្ភារៈសំណង់នៃដំបូល, ជញ្ជាំង និង/ឬកម្រាលផ្ទាល់ដី) |

| | |
|---|---|
| ១១ | គ្រួសារត្រូវបានរាយការណ៍ថាមិនបានបង្ខំចិត្តប្រើវិធីសាស្ត្រដោះស្រាយដែលមានហានិភ័យ ដើម្បីដោះស្រាយហានិភ័យក្នុងឆ្នាំកន្លងមក។ វិធីសាស្ត្រដែលមានហានិភ័យ ឬបង្គ្រោះថ្នាក់រួមមាន ការលក់ទ្រព្យសកម្ម, ការកាត់បន្ថយការទទួលទានអាហារ, កម្ចីដែលមានការប្រាក់ខ្ពស់/ពីអ្នកផ្តល់កម្ចីឯកជន, ការបញ្ឈប់កុមារពីការសិក្សា ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដូចជាការសុំទានជាដើម។ វិធីសាស្ត្រដោះស្រាយដែលមិនមានហានិភ័យមួយចំនួន រួមមានការប្រើប្រាស់ប្រាក់សន្សំផ្ទាល់ខ្លួន, ជំនួយពីសាច់ញាតិ និងមិត្តភក្តិ និងប្រាក់ចំណូលពីការងារ |
| ១២ | ស្ត្រីបានរាយការណ៍អំពីការលើកកម្ពស់សិទ្ធិអំណាច។ លទ្ធផលនេះអាចត្រូវបានវាស់វែងដោយស្វ័យភាពដោយពិនិត្យអំពីឯករាជ្យភាព, សុកមង្គល, ភាពពេញចិត្តក្នុងជីវិត, ការទទួលបានសេវាគាំទ្រថែទាំ, ហិង្សាពីដៃគូ (ការរំលោភបំពានលើផ្លូវអារម្មណ៍, ផ្លូវភេទ, រាងកាយ), លទ្ធភាពក្នុងការសម្រេចចិត្តដោយខ្លួនឯង, ចំនួនប្រាក់សន្សំសរុប ឬចំនួនទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយស្ត្រី |
| ១៣ | គ្រួសារមានប្រភពចំណូលយ៉ាងហោចណាស់ពីរ (យ៉ាងហោចណាស់មានសកម្មភាពចិញ្ចឹមជីវិតថ្មីមួយទៀតចាប់តាំងពីការវាយតម្លៃដើមគ្រា) ដើម្បីបង្ហាញពីពិពិធកម្មផ្នែកជីវភាព |